ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# គណិតវិទ្យា



$V = \pi r^2 h$

$V = \frac{4\pi r^3}{3}$

$\frac{2}{5} = 0.4 = \frac{40}{100} = 40\%$

$\frac{a}{b} = \frac{c}{d}$ ឬ $ad = bc$



៦

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

www.elibraryofcambodia.org

ក្រសួងអប់រំ យុវជន និងកីឡា

# គណិតវិទ្យា

## ថ្នាក់ទី ៦

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៨៥ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

**គណៈកម្មការនិពន្ធ** លោក ព្រុំ វិបុល លោក សួរ ច័ន្ទបូរី
លោក ភី ផន់ លោក ហាំ សេង

**អ្នកខាយអត្ថបទ** លោក ខែម ម៉ារី

**ចិចិត្រករ** លោក គន់ ជាតិ

**រៀបរៀង** លោក អ៊ិន គឹមស្រ៊ុន

**រចនាធំព័រ** លោក ខែម ម៉ារី

**គណៈកម្មការពិនិត្យ** លោក ឡុង សុផេង លោក ប៊ូ សន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២៥៧៣ អយក.ប្រក. ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ 2016

ISBN : 9-789-995-001-445

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅគណិតវិទ្យាថ្នាក់ទី៦ បានរៀបចំឡើងស្របតាមកម្មវិធីសិក្សាថ្មី ដែលចេញផ្សាយដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ។

ខ្លឹមសារសៀវភៅនេះ តម្រូវឱ្យសិក្សាអំពីចំនួនគត់ ចំនួនទសភាគ ប្រមាណវិធីលើប្រភាគ និងចំនួនចម្រុះ តួចែករួមធំបំផុត ពហុគុណរួមតូចបំផុត ផលធៀប សមាមាត្រ ភាគរយ ល្បឿន ផ្ទៃក្រឡា មាឌសូលីត ស្ថិតិ រង្វាស់ពេល ។ សៀវភៅនេះចែកចេញជា 20 មេរៀន ។

ការរៀបចំមេរៀននីមួយៗក្នុងសៀវភៅនេះចែកជា 3 ផ្នែកមានលំនាំដូចខាងក្រោម :

- មានរូបសញ្ញាសៀវភៅបើក សំគាល់ការផ្ដល់បញ្ញត្តិមេរៀន ។
- មានរូបសញ្ញាក្មេង សំគាល់លំហាត់សម្រាប់ពង្រឹងចំណេះដឹងសិស្ស ។
- រូបសញ្ញាក្មេងអមដោយសញ្ញាសួរ សំគាល់ផ្នែកចំណោទសម្រាប់ពង្រឹងការអនុវត្ត ។

សៀវភៅគណិតវិទ្យាថ្នាក់ទី៦នេះ ក៏មានការចូលរួមសាកល្បង និងផ្ដល់យោបល់កែលំអពីសំណាក់លោកគ្រូ អ្នកគ្រូសាលារៀនបឋមសិក្សានៅតាមបណ្ដាខេត្តមួយចំនួន និងគណៈកម្មការពិនិត្យ និងអនុម័តសៀវភៅរបស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅគណិតវិទ្យាថ្នាក់ទី៦ ដែលរៀបចំឡើងស្របតាមកម្មវិធីសិក្សាថ្មីនេះនឹងជួយប្អូនៗសិស្សានុសិស្សក្នុងការរៀនគណិតវិទ្យាឱ្យឆាប់ចេះគណនាលេខបានត្រឹមត្រូវ ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ជាឯកសារមួយដ៏មានសារៈសំខាន់សម្រាប់លោកគ្រូ អ្នកគ្រូផងដែរ ។

គណៈកម្មការនិពន្ធរង់ចាំទទួលរាល់មតិកែលំអបន្ថែម ពីសំណាក់អ្នកគ្រូ លោកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកអានពីគ្រប់មជ្ឈដ្ឋានទាំងអស់ដោយក្ដីសោមនស្សរីករាយ ។

គណៈកម្មការនិពន្ធ

www.elibraryofcambodia.org

# បញ្ជីអត្ថបទ


................................................ ទំព័រ

មេរៀនទី 1 : ចំនួន ..... 1

មេរៀនទី 2 : ចំនួនទសភាគ ..... 5

មេរៀនទី 3 : វិធីបូកនិងវិធីដកចំនួនទសភាគ ..... 9

មេរៀនទី 4 : កន្ទុះបន្ទាត់ពុះមុំនិងសំណង់មុំ ..... 19

មេរៀនទី 5 : ការជំនួសលេខដោយអក្សរ ..... 25

មេរៀនទី 6 : បរិមាត្រ ..... 29

មេរៀនទី 7 : ផ្ទៃក្រឡា ..... 33

មេរៀនទី 8 : វិធីគុណនិងវិធីចែកចំនួនទសភាគ ..... 43

មេរៀនទី 9 : តួចែករួមធំបំផុត-ពហុគុណរួមតូចបំផុត ..... 53

មេរៀនទី 10 : វិធីបូកនិងវិធីដកប្រភាគ ..... 63

មេរៀនទី 11 : វិធីគុណនិងវិធីចែកប្រភាគ ..... 79

មេរៀនទី 12 : ផលធៀប ..... 87

មេរៀនទី 13 : សមាមាត្រ ..... 91

មេរៀនទី 14 : ល្បឿន ..... 95

មេរៀនទី 15 : ប្រមាណវិធីលើចំនួនចម្រុះ ..... 99

មេរៀនទី 16 : ភាគរយ ..... 111

មេរៀនទី 17 : ការប្រាក់ ..... 115

មេរៀនទី 18 : ស្ថិតិ ..... 119

មេរៀនទី 19 : ប្រមាណវិធីលើរង្វាស់ពេល ..... 127

មេរៀនទី 20 : មាឌនិងផ្ទៃក្រឡាស៊ូលីត ..... 131


www.elibraryofcambodia.org




# ចំនួន

## អំណាននិងសំណេរចំនួន

ចំនួន 870 465 250

| ថ្នាក់លាន | | | ថ្នាក់ពាន់ | | | ថ្នាក់ឯកតា | | |
|---|---|---|---|---|---|---|---|---|
| លាន | | | សែន | ម៉ឺន | ពាន់ | រយ | ដប់ | រាយ |
| 8 | 7 | 0 | 4 | 6 | 5 | 2 | 5 | 0 |

គេអាចអានចំនួនខាងលើតាមខ្ទង់និងតាមថ្នាក់ដូចខាងក្រោម




- ប្រាំបីរយចិតសិបលាន បួនសែនប្រាំមួយម៉ឺន ប្រាំពាន់ពីររយហាសិប ។
- ប្រាំបីរយចិតសិបលាន បួនរយហុកសិបប្រាំពាន់ពីររយហាសិប ។

## លំហាត់

1. ចូរអានចំនួនរួចសរសេរពាក្យនៃចំនួនខាងក្រោមតាមខ្ទង់និងតាមថ្នាក់

ក. 125 243 102 ខ. 248 180 035 គ. 405 276 930

ឃ. 2871 135 463 ង. 4376 718 360 ច. 6053 871 189 ។

2. ចូរសរសេរចំនួនខាងក្រោម

ក. បីរយប៉ែតសិបប្រាំលាន ពីរសែនប្រាំម៉ឺនសាមសិបប្រាំ

ខ. ប្រាំរយហាសិបលាន បីរយប៉ែតសិបប្រាំពីរពាន់ ប្រាំមួយរយប្រាំពីរ ។



www.elibraryofcambodia.org

## ខ្ទង់និងតម្លៃលេខតាមខ្ទង់

តើតួលេខតាមខ្ទង់នីមួយៗនៃចំនួន 3 024 103 មានតម្លៃដូចម្ដេច ?




- លេខ 3 នៅខ្ទង់រាយមានតម្លៃ $3 \times 1 = 3$
- លេខ 0 នៅខ្ទង់ដប់មានតម្លៃ $0 \times 10 = 0$
- លេខ 1 នៅខ្ទង់រយមានតម្លៃ $1 \times 100 = 100$
- លេខ 4 នៅខ្ទង់ពាន់មានតម្លៃ $4 \times 1\,000 = 4\,000$
- លេខ 2 នៅខ្ទង់ម៉ឺនមានតម្លៃ $2 \times 10\,000 = 20\,000$
- លេខ 0 នៅខ្ទង់សែនមានតម្លៃ $0 \times 100\,000 = 0$
- លេខ 3 នៅខ្ទង់លានមានតម្លៃ $3 \times 1\,000\,000 = 3\,000\,000$

សរសេរជាទម្រង់ពន្លាតគឺ

$3\,024\,103 = 3\,000\,000 + 0 + 20\,000 + 4\,000 + 100 + 0 + 3$ ។

## លំហាត់

1. ចូរបំពេញចន្លោះខាងក្រោម

ចំនួន 80 250 346

លេខ 8 នៅខ្ទង់ដប់លានមានតម្លៃ ..................................................

លេខ 0 នៅខ្ទង់ពាន់មានតម្លៃ ..................................................

លេខ 5 នៅខ្ទង់ ................ មានតម្លៃ .................................... ។

2. ចូរសរសេរចំនួនខាងក្រោមជាទម្រង់ពន្លាត

ក. 15 721 540 ខ. 281 200 183 គ. 308 005 350 ។



www.elibraryofcambodia.org

## ការប្រៀបធៀបនិងរៀបលំដាប់ចំនួន

### ក. ការប្រៀបធៀប

តើចំនួន 3 256 401 និង 3 257 250 ណាមួយមានតម្លៃធំជាង ?

| លាន | សែន | ម៉ឺន | ពាន់ | រយ | ដប់ | រាយ |
|---|---|---|---|---|---|---|
| 3 | 2 | 5 | 6 | 4 | 0 | 1 |
| 3 | 2 | 5 | 7 | 2 | 5 | 0 |
| ⇧ | ⇧ | ⇧ | ⇧ | | | |
| 3 = 3 | 2 = 2 | 5 = 5 | 6 < 7 | | | |

ដូចនេះ 3 256 401 < 3 257 250 ឬ 3 257 250 > 3 256 401 ។

### ខ. ការរៀបលំដាប់

2 510 571 ; 2 538 505 ; 2 530 295 ; 263 895 ។

តើគេរៀបចំនួនខាងលើតាមលំដាប់ពីតូចទៅធំនិងពីធំទៅតូចដូចម្ដេច ?

ប្រៀបធៀបម្ដងពីរចំនួន 263 895 < 2 510 571

2 510 571 < 2 530 295

2 530 295 < 2 538 505 ។

លំដាប់ពីតូចទៅធំ 263 895 ; 2 510 571 ; 2 530 295 ; 2 538 505 ។

លំដាប់ពីធំទៅតូច 2 538 505 ; 2 530 295 ; 2 510 571 ; 263 895 ។

## លំហាត់

1. ចូរប្រៀបធៀបចំនួនខាងក្រោម

   ក. 5 420 350 និង 4 520 265

   ខ. 7 963 250 និង 7 959 870 ។

2. ចូររៀបលំដាប់ចំនួនខាងក្រោមពីតូចទៅធំនិងច្រាសមកវិញ

| 3 303 003 | ; | 3 300 033 | ; | 3 033 003 | ; | 3 300 303 | ។ |
|---|---|---|---|---|---|---|---|

www.elibraryofcambodia.org

## ការបង្គត់ចំនួន

ក. បង្គត់ចំនួន 2 782 150 ត្រឹមខ្ទង់លាន

2 782 150 ពិបាកចាំជាង 3 000 000 ។ ការបង្គត់គឺធ្វើឱ្យតម្លៃចំនួននោះជាតម្លៃប្រហែលនិងងាយចងចាំ ។






2 782 150 នៅជិត 3 000 000 ជាង 2 000 000 ។ ដូចនេះត្រូវបង្គត់ឡើងទៅ 3 000 000 ។ ចំនួន 2 782 150 បង្គត់ត្រឹមខ្ទង់លានគឺ 3 000 000 ។

ខ. បង្គត់ចំនួន 5 623 501 ត្រឹមខ្ទង់សែន




5 623 501 នៅជិត 5 600 000 ជាង 5 700 000 ។ ដូចនេះត្រូវបង្គត់ចុះទៅ 5 600 000 ។ ចំនួន 5 623 501 បង្គត់ត្រឹមខ្ទង់សែនគឺ 5 600 000 ។

ដើម្បីបង្គត់ចំនួនត្រូវមើលខ្ទង់ខាងស្តាំបន្ទាប់ដែលត្រូវបង្គត់

1. បើខ្ទង់នោះមានលេខ 0 ; 1 ; 2 ; 3 ; 4 ត្រូវបង្គត់ចុះ ។
2. បើខ្ទង់នោះមានលេខ 5 ; 6 ; 7 ; 8 ; 9 ត្រូវបង្គត់ឡើង ។

## លំហាត់

1. ចូរបង្គត់ចំនួនខាងក្រោមត្រឹមខ្ទង់លាន

   ក. 2 368 210 ខ. 6 871 955 គ. 8 593 456 ។

2. ប្រទេសកម្ពុជាមានប្រជាជន 13 395 682 នាក់ ។ ចូរបង្គត់ចំនួនត្រឹមខ្ទង់លាន ។
3. ប្រទេសកម្ពុជាមានផ្ទៃក្រឡា 181 035$km^2$ ។ ចូរបង្គត់ចំនួនត្រឹមខ្ទង់ម៉ឺន ។



www.elibraryofcambodia.org

# 2 ចំនួនទសភាគ

## អំណាននិងសំណេរចំនួនទសភាគ



សរសេរជាប្រភាគ $\frac{1025}{1000}$

សរសេរជាចំនួនទសភាគ 1.025

1.025 អានថាមួយចុចសូន្យម្ភៃប្រាំ ។



សរសេរជាប្រភាគ $\frac{135}{1000}$

សរសេរជាចំនួនទសភាគ 0.135

0.135 អានថាសូន្យចុចមួយរយសាមសិបប្រាំ ។

## លំហាត់

1. ចូរសរសេរចំនួនទសភាគតាងរូបខាងក្រោម

ក. 

ខ. 

គ. 

2. ចូរសរសេរប្រភាគខាងក្រោមជាចំនួនទសភាគ

ក. $\frac{152}{1000}$ ខ. $\frac{75}{1000}$ គ. $\frac{2630}{1000}$ ឃ. $\frac{35421}{1000}$ ។

3. ចូរសរសេរពាក្យអំណានចំនួនទសភាគខាងក្រោម

ក. 2.523 ខ. 0.075 គ. 40.360 ឃ. 68.005 ។

www.elibraryofcambodia.org

## ខ្ទង់និងតម្លៃលេខតាមខ្ទង់

តើតួលេខនីមួយៗនៃចំនួន 36.458 មានតម្លៃដូចម្តេច ?

| ផ្នែកគត់ | | | ចំណុច | ផ្នែកទសភាគ | | |
|---|---|---|---|---|---|---|
| រយ | ដប់ | រាយ | | ភាគដប់ | ភាគរយ | ភាគពាន់ |
| | 3 | 6 | • | 4 | 5 | 8 |

- 3 នៅខ្ទង់ដប់មានតម្លៃ $3\times 10 = 30$
- 6 នៅខ្ទង់រាយមានតម្លៃ $6\times 1 = 6$
- 4 នៅខ្ទង់ភាគដប់មានតម្លៃ $4\times\frac{1}{10} = 0.4$ ឬ $4\times 0.1 = 0.4$
- 5 នៅខ្ទង់ភាគរយមានតម្លៃ $5\times\frac{1}{100} = 0.05$ ឬ $5\times 0.01 = 0.05$
- 8 នៅខ្ទង់ភាគពាន់មានតម្លៃ $8\times\frac{1}{1000} = 0.008$ ឬ $8\times 0.001 = 0.008$

*សរសេរជាទម្រង់ពង្រាយគឺ* $36.458 = 30+6+0.4+0.05+0.008$ ។

## លំហាត់

1. ចូរបំពេញចន្លោះខាងក្រោម

ចំនួន 183.645

លេខ 1 នៅខ្ទង់រយមានតម្លៃ .................................... ។

លេខ 6 នៅខ្ទង់ ....................មានតម្លៃ ............................ ។

លេខ 4 នៅខ្ទង់ ....................មានតម្លៃ ............................ ។

2. ចូរប្រាប់ខ្ទង់និងតម្លៃតួលេខដែលគូសពីក្រោម

ក. $2.1\underline{3}5$ ខ. $43.\underline{2}50$ គ. $185.01\underline{5}$ ឃ. $0.6\underline{0}3$

ង. $4\underline{5}.308$ ច. $159.60\underline{7}$ ឆ. $0.\underline{0}39$ ជ. $0.0\underline{7}5$ ។



www.elibraryofcambodia.org

## ចំនួនទសភាគមានតម្លៃស្មើគ្នា

ឧទាហរណ៍ទី 1 :



$\frac{2}{10} = 0.2$



$\frac{20}{100} = 0.20$

តាមរូបយើងឃើញថា 0.2 = 0.20 ។

ឧទាហរណ៍ទី 2 : 0.9 = 0.90 = 0.900 ; 12.000 = 12.00 = 12.0 = 12 ។

> ការសរសេរលេខសូន្យបន្តពីក្រោយលេខនៅផ្នែកទសភាគមិនធ្វើឱ្យចំនួនទសភាគផ្លាស់ប្ដូរតម្លៃទេ ។

## ការបង្គត់ចំនួនទសភាគ

**ក. បង្គត់ 2.362 ត្រឹមខ្ទង់ភាគរយ**

នៅខ្ទង់ភាគពាន់មានតួលេខ 2 យើងត្រូវបង្គត់ចុះ ។ ដូចនេះ 2.362 បង្គត់ត្រឹមខ្ទង់ភាគរយគឺ 2.360 ឬ 2.36 ។

**ខ. បង្គត់ 15.385 ត្រឹមខ្ទង់ភាគដប់**

នៅខ្ទង់ភាគរយមានតួលេខ 8 យើងត្រូវបង្គត់ឡើង ។ ដូចនេះ 15.385 បង្គត់ត្រឹមខ្ទង់ភាគដប់គឺ 15.400 ឬ 15.4 ។

> ការបង្គត់ចំនួនទសភាគដូចគ្នានឹងការបង្គត់ចំនួនគត់ដែរ ។

## លំហាត់

1. ចូរបំពេញចន្លោះជាចំនួនទសភាគស្មើគ្នា

   ក. 0.50 = ...... = ......  ខ. 34.6 = ...... = ...... ។

2. ចូរបង្គត់ចំនួនខាងក្រោមត្រឹមខ្ទង់ភាគដប់និងខ្ទង់ភាគរយ

   ក. 0.851  ខ. 7.638  គ. 128.593 ។

www.elibraryofcambodia.org

# ការប្រៀបធៀបនិងរៀបលំដាប់ចំនួនទសភាគ

## ក. ការប្រៀបធៀប

តើចំនួន 36.272 និង 36.254 ណាមួយមានតម្លៃធំជាង ?

| ផ្នែកគត់ | | | ចំណុច | ផ្នែកទសភាគ | | |
|---|---|---|---|---|---|---|
| រយ | ដប់ | រាយ | | ភាគដប់ | ភាគរយ | ភាគពាន់ |
| | 3 | 6 | . | 2 | 7 | 2 |
| | 3 | 6 | | 2 | 5 | 4 |

3 = 3   6 = 6   2 = 2   7 > 5

ដូចនេះ 36.272 > 36.254 ឬ 36.254 < 36.272 ។

## ខ. ការរៀបលំដាប់

72.654 ; 72.683 ; 72.125 ; 73.109

តើចំនួនទសភាគខាងលើរៀបលំដាប់ដូចម្តេច ?

ប្រៀបធៀបម្តងពីរចំនួន

73.109 > 72.683 ; 72.683 > 72.654 ; 72.654 > 72.125

រៀបលំដាប់ពីតូចទៅធំគឺ 72.125 ; 72.654 ; 72.683 ; 73.109 ។

រៀបលំដាប់ពីធំទៅតូចគឺ 73.109 ; 72.683 ; 72.654 ; 72.125 ។

## លំហាត់

1. ចូរប្រៀបធៀបចំនួនទសភាគ ដោយប្រើសញ្ញា < ; > ឬ =

ក. 13.256 ☐ 13.248  ខ. 245.162 ☐ 245.159

គ. 85.65 ☐ 85.650  ឃ. 674.080 ☐ 674.80 ។

2. ចូររៀបលំដាប់ចំនួនទសភាគពីតូចទៅធំនិងច្រាសមកវិញ

ក. 78.086 ; 78.087 ; 78.305 ; 77.989

ខ. 185.306 ; 185.30 ; 185.285 ; 186.009 ។


www.elibraryofcambodia.org

# 3 វិធីបូកនិងវិធីដកចំនួនទសភាគ

## ការបូកចំនួនទសភាគនឹងចំនួនគត់

ម្ដាយស៊ីណាតត្បាញក្រមាថ្ងៃទី 1 បាន 15.545m ថ្ងៃទី 2 បាន 14m ។ តើម្ដាយស៊ីណាតត្បាញក្រមាទាំង 2 ថ្ងៃបានប្រវែងប៉ុន្មានម៉ែត្រ ?

15.545 + 14 = ☐

```
  15.545
+ 14.000
  ------
  29.545
```




ដូចនេះម្ដាយស៊ីណាតត្បាញក្រមាទាំង 2 ថ្ងៃបានប្រវែង 29.545m ។

ដើម្បីបូកចំនួនទសភាគនឹងចំនួនគត់ យើងត្រូវ

1. សរសេរចំនួនដែលជាតួបូកឱ្យត្រូវតាមខ្ទង់ ។
2. ថែមចំណុចទសភាគនិងសូន្យឱ្យចំនួនគត់ ដើម្បីបានចំនួនខ្ទង់នៅផ្នែកទសភាគដូចគ្នា ។
3. ធ្វើប្រមាណវិធីបូកដូចចំនួនគត់ រួចដាក់ចំណុចទសភាគនៅផលបូកឱ្យចំទីតាំងរបស់វា ។

## លំហាត់

ចូរគណនាផលបូក

ក. 52.425 + 19

ខ. 185.08 + 15

គ. 28 + 14.018

ឃ. 75.008 + 16 + 25

ង. 35 + 19.50 + 45

ច. 52 + 27.015 + 6.115

ឆ. 26.058 + 12 + 125 + 50.575

ជ. 80 + 16.108 + 25 + 7.215 ។

www.elibraryofcambodia.org

## ការបូកចំនួនទសភាគនិងចំនួនទសភាគ

ឧទាហរណ៍ 1 : 3.356 + 40.513 = ☐




$$\begin{array}{r} 3.356 \\ +\ 40.513 \\ \hline 43.869 \end{array}$$

ដូចនេះ 3.356 + 40.513 = 43.869 ។

ឧទាហរណ៍ 2 : 163.251 + 32.8 = ☐




$$\begin{array}{r} {}^{1}\phantom{00000} \\ 163.251 \\ +\ 32.800 \\ \hline 196.051 \end{array}$$

ដូចនេះ 163.251 + 32.8 = 196.051 ។

ដើម្បីបូកចំនួនទសភាគនិងចំនួនទសភាគ យើងត្រូវ

1. សរសេរចំនួនដែលជាតួបូកឱ្យត្រូវតាមខ្ទង់ ហើយចំណុចទសភាគឱ្យត្រង់គ្នាពីលើចុះក្រោម ។
2. ថែមសូន្យនៅខ្ទង់ទំនេរ ដើម្បីបានចំនួនខ្ទង់ស្មើគ្នា ។
3. ធ្វើប្រមាណវិធីបូកដូចចំនួនគត់រួចដាក់ចំណុចទសភាគនៅផលបូកឱ្យចំទីតាំង ។

## លំហាត់

ចូរគណនាផលបូក

ក. 31.255 + 5.815

ខ. 635.045 + 50.365

គ. 85.275 + 150.325

ឃ. 82.547 + 490.672

ង. 19.05 + 3.208

ច. 817.395 + 48.22

ឆ. 2.31 + 5.815 + 9.2

ជ. 38.2 + 191.413 + 25.25

ឈ. 765.3 + 60.813 + 7.96

ញ. 3.37 + 297.07 + 45.095 ។



www.elibraryofcambodia.org

## ការប៉ាន់ស្មានផលបូកចំនួនទសភាគ

ពូលីប្រមូលផលគ្រាប់កាហ្វេលើកទី 1 បាន 5.250kg លើកទី 2 បាន 4.35kg និង លើកទី 3 បាន 6.750kg ។ តើពូលីប្រមូលផលគ្រាប់កាហ្វេទាំង 3 លើកបានប្រហែលប៉ុន្មានគីឡូក្រាម ?

5.250 + 4.35 + 6.750 = ☐

$$\begin{array}{r} 5.250 \\ +\ 4.35 \\ 6.750 \\ \hline \end{array}$$

បង្គត់ទៅ

$$\begin{array}{r} 5 \\ +\ 4 \\ 7 \\ \hline 16 \end{array}$$



ដូចនេះ ពូលីប្រមូលផលគ្រាប់កាហ្វេទាំង 3 លើកបានប្រហែល 16kg ។

> ដើម្បីប៉ាន់ស្មានផលបូកចំនួនទសភាគយើងត្រូវបង្គត់ចំនួនទសភាគឱ្យទៅជាចំនួនគត់រួចធ្វើប្រមាណវិធីបូក ។

## លំហាត់

1. ចូរប៉ាន់ស្មានផលបូកចំនួនទសភាគ

ក. 4.25 + 6.115

ខ. 28.675 + 35.280

គ. 150.050 + 24.718

ឃ. 86.78 + 350.356

ង. 19.50 + 2.8 + 52.895

ច. 67.162 + 9.08 + 185.22 ។

2. ចូររកតម្លៃប្រហែលនៃផលបូកចំនួនទសភាគ

ក. 9.185 + 36.870

ខ. 97.09 + 0.89 + 2.43

គ. 23.365 + 7.75

ឃ. 8.25 + 16.17 + 7.1

ង. 6.775 + 4.21 + 8.65

ច. 8.45 + 7.56 + 22.25 ។

www.elibraryofcambodia.org

## ចំណោទ

1. ចតុកោណកែងមួយមានទទឹង 7dm 5cm 8mm និងបណ្តោយ 1.2m ។ គណនាប្រវែងជុំវិញចតុកោណកែងនោះគិតជាម៉ែត្រ ។




2. ពូសំលក់ស្រូវលើកទី 1 បាន 1.250 តោន លើកទី 2 បាន 2.550 តោន និងនៅលើកទី 3 បាន 3 តោន ។ តើគាត់លក់ស្រូវសរុបបានប៉ុន្មានតោន ?

3. គណនាប្រវែងផ្លូវពី A ទៅ B




4. ប្រជាជននៃភូមិមួយ លើកផ្លូវលំនៅខែទី1 បានប្រវែង 2.350km ខែទី2 បាន 1.53km ហើយនៅខែទី3 បាន 0.555km ។ តើពួកគាត់លើកផ្លូវលំសរុបបានប្រវែងប៉ុន្មានគីឡូម៉ែត្រ ?

5. កសិករម្នាក់ច្រកទឹកឃ្មុំចូលក្នុងដបបីដែលមានចំណុះ 0.33ℓ 0.75ℓ និង 1ℓ ។ តើទឹកឃ្មុំនោះសរុបមានប៉ុន្មានលីត្រ ?

6. ដបមួយមានទឹក 2ℓ និងកំសៀវមួយមានទឹក 1.250ℓ ច្រើនជាងទឹកក្នុងដប ។ តើទឹកក្នុងកំសៀវនិងក្នុងដបរួមគ្នាមានប៉ុន្មានលីត្រ ?

7. ដារីប្រើចំណីមាន់អស់ 2.525kg ប្រើចំណីទាលើសចំណីមាន់ 1.50kg និងប្រើចំណីជ្រូកអស់ 5kg ។ តើដារីប្រើចំណីសត្វសរុបអស់ប៉ុន្មានគីឡូក្រាម ?



www.elibraryofcambodia.org

# ការដកចំនួនទសភាគដែលផ្នែកទសភាគមានចំនួនខ្ទង់ស្មើគ្នា

ផ្លូវលំមួយមានប្រវែង 35.765km ។ គេក្រាលកៅស៊ូបានប្រវែង 28.565km ។ តើផ្លូវលំនោះនៅសល់ប្រវែងប៉ុន្មានទៀតដែលមិនទាន់ក្រាលកៅស៊ូ ?

35.765 – 28.565 = ☐




$$\begin{array}{r} \overset{2\ 15}{35.765} \\ -\ 28.565 \\ \hline 07.200 \end{array}$$

ដូចនេះ ផ្លូវលំមិនទាន់ក្រាលកៅស៊ូមានប្រវែង 7.200km ឬ 7.2km ។

ដើម្បីដកចំនួនទសភាគដែលផ្នែកទសភាគមានចំនួនខ្ទង់ស្មើគ្នា យើងត្រូវ

1. សរសេរចំនួនដែលជាតួដកឱ្យត្រូវតាមខ្ទង់ ហើយចំណុចទសភាគឱ្យត្រង់គ្នាពីលើចុះក្រោម ។
2. ធ្វើប្រមាណវិធីដកដូចចំនួនគត់រួចដាក់ចំណុចទសភាគនៅផលដកឱ្យចំទីតាំងរបស់វា ។

## លំហាត់

ចូរគណនាផលដក

ក. 0.523 – 0.265
ខ. 0.925 – 0.670
គ. 1.265 – 0.925
ឃ. 5.205 – 3.608
ង. 8.660 – 5.335
ច. 10.505 – 8.264
ឆ. 21.396 – 18.283
ជ. 52.005 – 25.205
ឈ. 63.512 – 19.205
ញ. 252.125 – 125.205 ។



www.elibraryofcambodia.org

## ការដកចំនួនទសភាគដែលផ្នែកទសភាគមានចំនួនខ្ទង់មិនស្មើគ្នា

បូណាមានទម្ងន់ 32.55kg ។ ដារីមានទម្ងន់ 29.245kg ។ តើបូណាមានទម្ងន់ធ្ងន់ជាងដារីប៉ុន្មានគីឡូក្រាម ?

32.55 − 29.245 = □

```
   2 12  4 10
   32.550
 − 29.245
 --------
   03.305
```




ដូចនេះ បូណាមានទម្ងន់ធ្ងន់ជាងដារី 3.305kg ។

ដើម្បីដកចំនួនទសភាគដែលផ្នែកទសភាគមានចំនួនខ្ទង់មិនស្មើគ្នា យើងត្រូវ

1. សរសេរចំនួនដែលជាតួដកឱ្យត្រូវតាមខ្ទង់ហើយចំណុចទសភាគឱ្យត្រង់គ្នាពីលើចុះក្រោម ។
2. ថែមសូន្យឱ្យផ្នែកទសភាគដើម្បីមានចំនួនខ្ទង់ស្មើគ្នា ។
3. ធ្វើប្រមាណវិធីដកដូចចំនួនគត់រួចដាក់ចំណុចទសភាគនៅផលដកឱ្យចំទីតាំងរបស់វា ។

## លំហាត់

ចូរគណនាផលដក

ក. 15.25 − 7.155

ខ. 26.335 − 18.26

គ. 41.2 − 38.253

ឃ. 53.450 − 33.5

ង. 9.3 − 5.350

ច. 34.45 − 28.118

ឆ. 25.135 − 18.5

ជ. 87.40 − 46.855

ឈ. 125.5 − 50.25 − 32.175

ញ. 8. − 5.315 − 0.95

ដ. 12.65 − 7.675 − 0.75

ឋ. 250.85 − 65.8 − 42.356 ។



www.elibraryofcambodia.org

# ការដកចំនួនគត់និងចំនួនទសភាគ

ម្ដាយធីតាទិញប្រេងឆា 5ℓ ។ គាត់ប្រើប្រាស់អស់ 2.245ℓ ។ តើប្រេងឆានៅសល់ប៉ុន្មានលីត្រ ?

5 – 2.245 = ☐

```
      9 10
    9 10
  4 10
  5.000
– 2.245
-------
  2.755
```




ដូចនេះ ប្រេងឆានៅសល់ 2.755ℓ ។

ដើម្បីដកចំនួនគត់និងចំនួនទសភាគ យើងត្រូវ

1. សរសេរចំនួនដែលជាតួដកឱ្យត្រូវតាមខ្ទង់ ។
2. ថែមចំណុចទសភាគនិងសូន្យឱ្យចំនួនគត់ដើម្បីបានចំនួនខ្ទង់នៅផ្នែកទសភាគដូចគ្នា ។
3. ធ្វើប្រមាណវិធីដកដូចចំនួនគត់រួចដាក់ចំណុចទសភាគនៅផលដកឱ្យចំទីតាំងរបស់វា ។

## លំហាត់

ចូរធ្វើប្រមាណវិធីខាងក្រោម

ក. 2 – 0.750

ខ. 8 – 5.185

គ. 15 – 9.362

ឃ. 28 – 12.975

ង. 10 – 7.250

ច. 25 – 6.815

ឆ. 15.550 – 10

ជ. 95.365 – 70

ឈ. 10 – 2.530 – 3

ញ. 40 – 15.550 – 8.005

ដ. 64 – 25.435 – 2.812

ឋ. 164 – 125.234 – 2.812 ។



www.elibraryofcambodia.org

# ការប៉ាន់ស្មានផលដកចំនួនទសភាគ

ពូសំតាមដានការលូតលាស់កូនជ្រូកដែលមានលទ្ធផលដូចតទៅ ៖ ខែទី 1 កូនជ្រូកមានទម្ងន់ 10.752kg និងខែទី 2 កូនជ្រូកមានទម្ងន់ 15.145kg ។ តើក្នុងមួយខែកូនជ្រូករបស់គាត់ឡើងទម្ងន់ប្រហែលប៉ុន្មានគីឡូក្រាម ?

15.145 – 10.725 = ☐

$$\begin{array}{r} 15.145 \\ -\ 10.725 \\ \hline \end{array} \quad \xrightarrow{\text{បង្គត់ទៅ}} \quad \begin{array}{r} 15 \\ -\ 11 \\ \hline 4 \end{array}$$



ដូចនេះ ក្នុងមួយខែកូនជ្រូករបស់ពូសំឡើងទម្ងន់បានប្រហែល 4kg ។

> ដើម្បីប៉ាន់ស្មានផលដកចំនួនទសភាគ យើងត្រូវបង្គត់ចំនួនទសភាគឱ្យទៅជាចំនួនគត់រួចធ្វើប្រមាណវិធីដក ។

## លំហាត់

1. ចូរប៉ាន់ស្មានផលដកខាងក្រោម

ក. 3.150 – 1.750 ខ. 8.825 – 4.760 គ. 12.689 – 8.235

ឃ. 58.305 – 32.910 ង. 185.090 – 89.875 ច. 250.750 – 125.370

ឆ. 25.90 – 8 – 9.315 ជ. 32.216 – 15 – 6.760 ឈ. 40.015 – 8.75 – 10 ។

2. ចូររកតម្លៃប្រហែលនៃផលដកខាងក្រោម

ក. 28.075 – 25.75 ខ. 9.8 – 7.215

គ. 9.85 – 1.230 ឃ. 12.050 – 9.87

ង. 10 – 8.95 – 0.75 ច. 15.75 – 6.125 – 5

ឆ. 15 – 8.50 – 3.125 ជ. 20.5 – 11.85 – 5.265

ឈ. 25 – 12.6 – 8.055 ញ. 28.19 – 15.85 – 5.250

ដ. 30 – 15.8 – 2.250 ឋ. 35 – 20.215 – 8.750 ។



www.elibraryofcambodia.org

## ចំណោទ

1. គេយកត្រីងៀតទម្ងន់ 10.545kg ទៅហាល ។ នៅពេលស្ងួតត្រីងៀតនៅសល់ទម្ងន់តែ 6.765kg ។ តើត្រីងៀតស្រកទម្ងន់អស់ប៉ុន្មានគីឡូក្រាម ?
2. សុខាមានទម្ងន់ 35kg ។ ធីតាមានទម្ងន់ 29.25kg ។ តើសុខាមានទម្ងន់ធ្ងន់ជាងធីតាប៉ុន្មានគីឡូក្រាម ?
3. គេថ្លឹងផ្អកមួយកែវមានទម្ងន់ 3.350kg ។ បន្ទាប់មក គេថ្លឹងសំបកកែវឃើញមានទម្ងន់ 0.450kg ។ តើផ្អកសុទ្ធមានទម្ងន់ប៉ុន្មានគីឡូក្រាម ?
4. គេសង់ផ្លូវមួយមានប្រវែង 90km ។ លើកទី 1 គេសង់បាន 25.525km ហើយលើកទី 2 គេសង់បាន 23.875km ។ តើនៅសល់ផ្លូវប្រវែងប៉ុន្មានគីឡូម៉ែត្រទៀតដែលត្រូវសង់បន្ថែម ?
5. មីងនីទិញសាច់គោ 3.5kg ។ គាត់យកទៅប្រឡាក់អស់ 1.25kg និងយកទៅឆាអស់ 0.50kg ។ តើសាច់គោនៅសល់មានទម្ងន់ប៉ុន្មានគីឡូក្រាម ?
6. គេយកម្សៅមី 1 បាវទម្ងន់ 50kg ទៅធ្វើនំប៉័ងអស់ 25.50kg ធ្វើនំបាវអស់ 12.250kg និងធ្វើនំឆាខ្វៃអស់ 10kg ។ តើគេនៅសល់ម្សៅមីប៉ុន្មានគីឡូក្រាមទៀត ?
7. ពូចាន់ទិញមាន់ 1 ក្បាល ទា 1 ក្បាល និងក្ងាន 1 ក្បាល ។ ទាមានទម្ងន់ 2.50kg មាន់មានទម្ងន់ស្រាលជាងទា 0.75kg ។ គេដឹងថាសត្វទាំង 3 ក្បាលមានទម្ងន់ 6.525kg ។ តើសត្វក្ងានមានទម្ងន់ប៉ុន្មានគីឡូក្រាម ។
8. ពូសំលក់ស្រូវ 32.350 តោន ។ ពូធនលក់ស្រូវតិចជាងពូសំ 1.525 តោន ប៉ុន្តែច្រើនជាងពូទា 1.135 តោន ។ តើពូធននិងពូទាបានលក់ស្រូវប៉ុន្មានតោន ?
9. គេមានអង្ករ 50 តោន ។ គេលក់លើកទី 1 អស់ 15.500 តោន ហើយលក់លើកទី 2 បានច្រើនជាងលើកទីមួយចំនួន 12.500 តោន ។ តើគេនៅសល់អង្ករប៉ុន្មានតោន ?



www.elibraryofcambodia.org

10. ពូតារាមានទឹកប្រាក់ក្នុងទូរស័ព្ទរបស់គាត់ 0.25 $ ។ គាត់បញ្ចូលកាតតម្លៃ 5 $ ថែមទៀត ។ គាត់ទូរស័ព្ទទៅប្រពន្ធគាត់អស់ប្រាក់ 0.750 $ ទូរស័ព្ទទៅកូនគាត់អស់ប្រាក់ 1.05 $ និងផ្ញើសារទៅមិត្តភក្តិអស់ប្រាក់ 0.50 $ ។ តើនៅក្នុងទូរស័ព្ទរបស់គាត់នៅសល់ប្រាក់ប៉ុន្មានដុល្លារ ?

11. ធំបីកញ្ចប់រួមគ្នាមានទម្ងន់ 8.125kg ។ គេដឹងថាកញ្ចប់ទីមួយមានទម្ងន់ 2.750kg ហើយកញ្ចប់ទីពីរមានទម្ងន់ស្រាលជាងកញ្ចប់ទីមួយ 0.250kg ។ រកទម្ងន់កញ្ចប់ធំទីបី ។

12. កំណាត់សំពត់មួយផាប់មានប្រវែង 20m ។ គេកាត់លក់លើកទីមួយអស់ 4.535m កាត់លក់លើកទីពីរច្រើនជាងលើកទីមួយ 2.250m ហើយកាត់លក់លើកទីបីតិចជាងលើកទីមួយ 1.750m ។ រកប្រវែងកំណាត់សំពត់ដែលនៅសល់ ។

13. មីងណៃមានទម្ងន់ 65.25kg ហើយមីងណាតមានទម្ងន់ 63.50kg ។ បន្ទាប់ពីហាត់ប្រាណមួយរយៈ មីងណៃនៅសល់ទម្ងន់ 62.50kg ហើយមីងណាតនៅសល់ទម្ងន់ 60.10kg ។ តើនរណាបានស្រកទម្ងន់ច្រើនជាង ? ច្រើនជាងប៉ុន្មានគីឡូក្រាម ?

14. ចតុកោណព្នាយមួយមានប្រវែងជុំវិញ 13m ហើយមានជ្រុង 2.34m ; 3m និង 4.5m ។ គណនារង្វាស់ជ្រុងមួយទៀត ។




15. ឈើពីរដើមដាក់បន្តគ្នាមានប្រវែង 8.45m ឈើទីមួយមានប្រវែងខ្លីជាងឈើទីពីរ 2.53m ។ រកប្រវែងឈើទីមួយនិងទីពីរ ។




16. បូណាចូលហាងទិញទំនិញបីមុខ A ; B និង C ។ ទំនិញ A ថ្លៃ 1.24 $ B ថ្លៃ 3.05 $ និង C មិនបានចាំតម្លៃ ពេលគិតលុយសរុបឃើញ 7.74 $ ។ រកតម្លៃទំនិញ C ។



www.elibraryofcambodia.org

# 4 កន្លះបន្ទាត់ពុះមុំនិងសំណង់មុំ

## កន្លះបន្ទាត់ពុះមុំ

យើងមានមុំ ACB ។ កន្លះបន្ទាត់ CD ចែកមុំ ACB ជាពីរស្មើគ្នាគឺមុំ ACD និងមុំ BCD ។

ដូចនេះ កន្លះបន្ទាត់ CD ហៅថាកន្លះបន្ទាត់ពុះមុំ ACB ។




> កន្លះបន្ទាត់ពុះមុំគឺជាកន្លះបន្ទាត់ដែលគូសចេញពីកំពូលនៃមុំហើយចែកមុំជាពីរប៉ុនគ្នា ។

## លំហាត់

តើរូបណាខ្លះមានកន្លះបន្ទាត់ពុះមុំ ?

ក.




ខ.




គ.




ឃ.




www.elibraryofcambodia.org

# សំណង់កន្លះបន្ទាត់ពុះមុំ

សង់កន្លះបន្ទាត់ពុះមុំដោយ ប្រើបន្ទាត់និងដែកឈាន ។ ឧទាហរណ៍គេឱ្យមុំ ABC ។ ចូរគូសកន្លះបន្ទាត់ BD ពុះមុំ ABC









**ជំហានទី 1**

ដាក់ចុងដែកឈានឱ្យចំកំពូលមុំ រួចគូសធ្នូកាត់ជ្រុង BA និង BC ត្រង់ P និង Q ។




**ជំហានទី 2**

គូសធ្នូពីរបន្ថែមទៀតដែល មានផ្ចិត P និង Q ដោយឱ្យធ្នូ ទាំងពីរកាត់គ្នាត្រង់ D ។




**ជំហានទី 3**

គូសភ្ជាប់ពី B ទៅ D យើង បាន BD ជាកន្លះបន្ទាត់ពុះមុំ ABC ។



www.elibraryofcambodia.org

## លំហាត់

1. ចូរគូសកន្លះបន្ទាត់ពុះមុំខាងក្រោម




2. ចូរគូសកន្លះបន្ទាត់ OA ពុះមុំ XOY និង OB ពុះមុំ YOZ ដោយប្រើដែកឈាននិងបន្ទាត់ ។




www.elibraryofcambodia.org

## សំណង់មុំ ៦០° ដោយប្រើដែកឈាននិងបន្ទាត់

ដើម្បីសង់មុំ ៦០° ដោយប្រើដែកឈាននិងបន្ទាត់យើងត្រូវសង់តាមជំហានដូចខាងក្រោម ៖




**ជំហានទី 1**

គូសកន្លះបន្ទាត់ OX រួចគូសធ្នូផ្ចិត O កាត់ OX ត្រង់ A ។




**ជំហានទី 2**

រក្សាគំលាតដែកឈានឱ្យនៅដដែលរួចគូសធ្នូផ្ចិត A កាត់ធ្នូផ្ចិត O ត្រង់ B ។




**ជំហានទី 3**

គូសភ្ជាប់ពី O ទៅ B យើងបានមុំ XOY មានរង្វាស់ស្មើនឹង 60° ។



www.elibraryofcambodia.org

## លំហាត់

1. ចូរសង់មុំ 60° តាមរូបដែលឱ្យដោយកំណត់ O ជាកំពូលមុំ ។




2. ចូរសង់មុំ AOB = 60° រួចសង់កន្លះបន្ទាត់ OX ពុះមុំនេះ ។
3. ចូរសង់អង្កត់ AB = 5cm បន្ទាប់មកសង់មុំ ABC = 60° និងមុំ BAC = 60° ដោយកំណត់ A និង B ជាកំពូលមុំ ។
4. សង់មុំ 60° តាមរូបដែលឱ្យ ដោយយក O ជាកំពូល និងជ្រុងនៃមុំស្មើនឹង OA សង់មុំ 60° បន្តរៀងគ្នាតាមទិសដៅទ្រនិចនាឡិកា ។




ក. តើបានមុំ 60° ចំនួនប៉ុន្មាន ?

ខ. គូសភ្ជាប់ចុងនៃអង្កត់ដែលជាជ្រុងនៃមុំទាំងនោះ តើបានត្រីកោណប៉ុន្មាន ? តើត្រីកោណទាំងនោះជាប្រភេទត្រីកោណអ្វី ?

5. សង់មុំ ABC = 60° តាមរូបដែលឱ្យ រួចសង់កន្លះបន្ទាត់ BT ពុះមុំ CBD ។




ក. ប្រៀបធៀបរង្វាស់មុំ ABC មុំ CBT និងមុំ TBD ។ ដោយប្រើរ៉ាប់ទ័រ ផ្ទៀងផ្ទាត់ ។

ខ. គណនាផលបូកមុំ ABC + CBT + TBD ។

www.elibraryofcambodia.org

## សំណង់មុំ 90° ដោយប្រើបន្ទាត់និងដែកឈាន

ដើម្បីសង់មុំ 90° ដោយប្រើដែកឈាននិងបន្ទាត់យើងត្រូវសង់តាមជំហានដូចខាងក្រោម ៖

| | |
|---|---|
|  | **ជំហានទី 1**<br>គូសបន្ទាត់ AB |
|  | **ជំហានទី 2**<br>គូសធ្នូផ្ចិត A និង B (ដោយរក្សាគំលាតដែកឈាននៅដដែល)កាត់គ្នាត្រង់ M និង N ។ |
|  | **ជំហានទី 3**<br>គូសភ្ជាប់ពី M ទៅ N កាត់ AB ត្រង់ O យើងបានមុំកែង ឬមុំ 90° ចំនួនបួនគឺមុំ BOM មុំ AOM មុំ AON និងមុំ BON ។ |

## លំហាត់

ចូរសង់មុំ 90° តាមរូបដែលឱ្យដោយយក O ជាកំពូល

| | | |
|---|---|---|
| ក.  | ខ.  | គ.  |



www.elibraryofcambodia.org

# 5 ការជំនួសលេខដោយអក្សរ

## ផលបូកតួដូចគ្នា វិធីបូកនិងដកតួអក្សរ

### ក. ផលបូកតួដូចគ្នា

$5+5+5+5 = 4\times5$

ជំនួស 5 ដោយ a

$a+a+a+a = 4a$



**4a**

4a សំគាល់ថា 4 គុណនឹង a

ចំនួន 4 ហៅថាមេគុណ

អក្សរ a ហៅថាកត្តា ។

### ខ. វិធីបូកនិងដកតួអក្សរ

$$2n+4n = (2+4)n$$
$$= 6n$$

ដូចនេះ

$$2n+4n = 6n$$

$$5n-3n = (5-3)n$$
$$= 2n$$

ដូចនេះ

$$5n-3n = 2n$$ ។

www.elibraryofcambodia.org

## លំហាត់

1. សរសេរផលបូកទៅជាផលគុណ

ក. $n+n+n$ ខ. $b+b+b+b+b$

គ. $x+x+x+x$ ឃ. $t+t+t+t+t+t$ ។

2. សរសេរផលគុណទៅជាផលបូក

ក. $2b$ ខ. $4t$ គ. $5a$ ឃ. $7n$ ។

3. គណនា

ក. $7n$ ចំពោះ $n = 5$ ខ. $8a$ ចំពោះ $a = 3$

គ. $4t$ ចំពោះ $t = 2$ ឃ. $3x$ ចំពោះ $x = 15$ ។

4. គណនា

ក. $7a+4a$ ខ. $5t+2t$ គ. $a+11a$ ឃ. $7x+x$ ។

5. គណនា

ក. $11x-5x$ ខ. $7a-5a$ គ. $8n-7n$ ឃ. $6t-4t$ ។

## តម្លៃលេខនៃតួអក្សរ

ក. រក $n$ ដើម្បីឱ្យ $n-3 = 5$




$n-3 = 5$

$n = 5+3$

ដូចនេះ $n = 8$ ។

$$\begin{array}{r} n-3 = 5 \\ +3 = +3 \\ \hline n = 8 \end{array}$$



www.elibraryofcambodia.org

ខ. រក n ដើម្បីឱ្យ $n+5 = 9$

$$n = 9-5 = 4$$

ដូចនេះ $n = 4$ ។

$$\begin{aligned} n+5 &= 9 \\ -5 &= -5 \\ \hline n &= 4 \end{aligned}$$

គ. រក n ដើម្បីឱ្យ $\frac{n}{3} = 12$

$$n = 12 \times 3$$

ដូចនេះ $n = 36$ ។

$$\frac{n}{3} = 12$$
$$\frac{n}{3} \times 3 = 12 \times 3$$
$$n = 36$$

ឃ. រក n ដើម្បីឱ្យ $2n = 10$

ដូចនេះ $n = 5$ ។

$$2n = 10$$
$$\frac{2n}{2} = \frac{10}{2}$$
$$n = 5$$

បើយើងបូក ដក គុណ ឬចែកអង្គទាំងពីរនឹងចំនួនតែមួយនោះអង្គទាំងពីរនៅតែស្មើគ្នាដដែល ។

## លំហាត់

1. កំណត់ n ដែល

   ក. $n+7 = 9$  ខ. $3+n = 20$  គ. $13 = 5+n$  ឃ. $17 = n+1$ ។

2. កំណត់ x ដែល

   ក. $3x+1 = 13$  ខ. $7+2x = 15$  គ. $15 = 6x+1$  ឃ. $4+2x = 9$ ។

3. កំណត់ t ដែល

   ក. $5t = 3t+6$  ខ. $4t = 3t+12$  គ. $3t = t+8$  ឃ. $7t = t+60$ ។

4. កំណត់ a ដែល

   ក. $2(5+a) = 15$  ខ. $3(a+2) = 18$  គ. $5a = 3(a+4)$  ឃ. $4(9+a) = 6a$ ។



www.elibraryofcambodia.org

## របៀបដោះស្រាយចំណោទ

ឧទាហរណ៍1: 5 ថែមនឹងប៉ុន្មានទើបស្មើនឹង 9 ?

ចម្លើយ : តាង n ជាចំនួនដែលត្រូវថែម

$5 + n = 9$

$n = 9 - 5 = 4$

ដូចនេះ $n = 4$ ។

ផ្ទៀងផ្ទាត់ $5 + 4 = 9$

ឧទាហរណ៍2: ផលបូកនៃពីរចំនួនគត់តគ្នាស្មើនឹង 11 ។ចូរកំណត់ពីរចំនួននោះ ។

ចម្លើយ : ពីរចំនួនគត់តគ្នាកំណត់ដោយ n និង $n + 1$

ផលបូកវាស្មើនឹង 11

$n + n + 1 = 11$

$2n + 1 = 11$

$2n = 11 - 1$

$2n = 10$

$n = 10 \div 2 = 5$

ពីរចំនួននោះគឺ 5 និង 6 ។

ផ្ទៀងផ្ទាត់ $5 + 6 = 11$

## ចំណោទ

1. បីដងនៃមួយចំនួនស្មើនឹង 15 ។ រកចំនួននោះ ។
2. 5 ថែមនឹងពីរដងនៃ n ស្មើនឹង 13 ។ រក n ។
3. ផលបូកនៃបីចំនួនគត់តគ្នា ស្មើនឹង 36 ។ រកបីចំនួននោះ ។
4. ចំនួន n ថែមឱ្យ 5 ដកនឹង 1 ស្មើនឹង 11 ។
   ចូររក n ។
5. ចំនួន m គុណនឹង 3 ដកនឹង 2 ស្មើនឹង 4 ។ ចូររក m ។



www.elibraryofcambodia.org

# 6 បរិមាត្រ

## បរិមាត្រ




ប្រវែងដែលព័ទ្ធជុំវិញ រូបនេះហៅថា បរិមាត្រ ។

$P = 2 + 3 + 3 + 3 + 4.5 = 15.5cm$ ។

## រូបមន្តបរិមាត្រ

### ក. បរិមាត្រចតុកោណកែង




បើ a ជាទទឹងនិង b ជាបណ្ដោយនៃចតុកោណកែង

គេបាន : $P = a + b + a + b$

$P = 2a + 2b$ ឬ $P = 2(a + b)$ ។

បរិមាត្រចតុកោណកែង = (បណ្ដោយ + ទទឹង) × 2

$P = (a + b) \times 2$

### ខ. បរិមាត្រនៃការេ




បើ a ជាជ្រុងនៃការេ គេបាន : $P = a + a + a + a$

$P = 4a$ ។

បរិមាត្រការេ = ជ្រុង × 4

$P = a \times 4$

www.elibraryofcambodia.org

## លំហាត់

1. គណនាបរិមាត្រ ។

ក.




ខ.




2. គណនាបរិមាត្រ ។

ក.




ខ.




3. គេមានខ្សែលួស 84m ។ តើគេអាចព័ទ្ធជុំវិញរូបចតុកោណកែងនេះបានប៉ុន្មានជុំ ?




4. គណនាបរិមាត្រនៃរូបខាងក្រោម ។






www.elibraryofcambodia.org

## បរិមាត្រថាស




បរិមាត្ររង្វង់ដែលមានកាំ 4cm ត្រូវខ្លីជាងបរិមាត្រការេដែលមានជ្រុង 8cm ។

បរិមាត្រនៃការេ $4 \times 8 = 32cm$

ដូចនេះ បរិមាត្ររង្វង់ $P < 32cm$ ។

គេអាចរមៀលថាសមួយជុំដើម្បីកំណត់រកប្រវែងបរិមាត្រថាសតាមបន្ទាត់ក្រិតមួយដូចរូបខាងក្រោម



| អង្កត់ផ្ចិត | ប្រវែងមួយជុំនៃថាស | ផលធៀប |
|---|---|---|
| 3cm | 9.43cm | $\frac{9.43}{3} = 3.143$ |
| 4cm | 12.57cm | $\frac{12.57}{4} = 3.143$ |
| 5cm | 15.71cm | $\frac{15.71}{5} = 3.143$ |

ជាទូទៅគេយក $\pi = 3.14$ ជាតម្លៃប្រហែលនៃផលធៀប គេបានបរិមាត្រនៃរង្វង់ដែលមានអង្កត់ផ្ចិត D នោះ $P = D\pi$ (សញ្ញា $\pi$ អានថាផៃ ឬ ពី)

បើ R ជាកាំនៃរង្វង់នោះ $P = 2\pi R$ ព្រោះ $D = 2R$ ។

បរិមាត្ររង្វង់ = អង្កត់ផ្ចិត $\times \pi = 2\times$ កាំ $\times \pi$

$$P = D\pi = 2\pi R$$

www.elibraryofcambodia.org

## លំហាត់

1. គណនាបរិមាត្ររង្វង់ ។

ក.




ខ.




2. គណនាបរិមាត្ររូបដែលផ្គុំដោយកន្លះរង្វង់ និងចតុកោណកែង ។




3. កង់ A វិលបាន 7 ជុំក្នុង 1mn រីឯកង់ B វិលបាន 4 ជុំក្នុង 1mn ។ តើកង់ណាវិលបានប្រវែង វែងជាង ?

A




B




4. គេមានខ្សែប្រវែង 3 140cm ។ តើគេអាចយកខ្សែនេះទៅរុំស៊ីឡាំងនេះបានប៉ុន្មានជុំ ?




5. រង្វង់មួយមានបរិមាត្រ 13.188m ។ រកប្រវែងកាំរង្វង់នេះ ។



www.elibraryofcambodia.org

# 7 ផ្ទៃក្រឡា

## ឯកតានៃខ្នាតសម្រាប់វាស់ផ្ទៃក្រឡា




ចំពោះផ្ទៃតូច គេប្រើ 1cm² ធ្វើជាឯកតានៃខ្នាត ។ 1cm² គឺជាការេដែលមានរង្វាស់ជ្រុងស្មើនឹង 1cm ។




ចំពោះផ្ទៃធំ គេប្រើ 1m² ធ្វើជាឯកតានៃខ្នាត ។ 1m² គឺជាការេដែលមានរង្វាស់ជ្រុងស្មើនឹង 1m ។




បើការេមួយមានជ្រុងប្រវែង1m នោះផ្ទៃក្រឡាគឺ

$1m \times 1m = 1m^2$

$1m^2 = 1ca$ (1ca អានថា មួយសង់ទីអា) ។

បើការេមួយមានជ្រុងប្រវែង10m នោះផ្ទៃក្រឡាគឺ

$10m \times 10m = 100m^2$ ; $100m^2 = 1a$ (1a អានថា មួយអា) ។

បើការេមួយមានជ្រុងប្រវែង100m នោះផ្ទៃក្រឡាគឺ

$100m \times 100m = 10000m^2$ ; $10000m^2 = 1ha$ (1ha អានថា មួយហិកតា) ។

| | ha | a | ca | | | |
|---|---|---|---|---|---|---|
| $km^2$ | $hm^2$ | $dam^2$ | $m^2$ | $dm^2$ | $cm^2$ | $mm^2$ |
| 1 | 00 | 00 | 00 | 00 | 00 | 00 |
| | 1 | 00 | 00 | 00 | 00 | 00 |
| | | 1 | 00 | 00 | 00 | 00 |
| | | | 1 | 00 | 00 | 00 |
| | | | | 1 | 00 | 00 |
| | | | | | 1 | 00 |



www.elibraryofcambodia.org

# ផ្ទៃក្រឡាចតុកោណកែង




គណនាផ្ទៃក្រឡាចតុកោណកែងដែលមានទទឹង 3cm និងបណ្ដោយ 4cm ។

ក្នុងចតុកោណកែងគេរាប់ឃើញមាន $12cm^2$ ។

គេអាចគណនាផ្ទៃក្រឡាដោយយកទទឹងគុណនឹងបណ្ដោយគឺ $3 \times 4 = 12cm^2$ ។ជាទូទៅ :

បើ $a$ និង $b$ ជារង្វាស់ជ្រុងហើយ $A$ ជាផ្ទៃក្រឡាចតុកោណកែង នោះផ្ទៃក្រឡាចតុកោណកែងកំណត់ដោយ $A = a \times b$ ។

ផ្ទៃក្រឡាចតុកោណកែង = បណ្ដោយ × ទទឹង

ឬ $A = a \times b$

បើ $a$ ជារង្វាស់ជ្រុងហើយ $A$ ជាផ្ទៃក្រឡាការេ នោះ ផ្ទៃក្រឡាការេកំណត់ដោយ $A = a \times a$ ។

ផ្ទៃក្រឡាការេ = ជ្រុង × ជ្រុង

ឬ $A = a \times a$

## លំហាត់

1. ចូរបំពេញចំណុច

ក. $1km^2 = ...m^2$

ខ. $1km^2 = ...ha$

គ. $3ha\ 25a\ 7ca = ...m^2$

ឃ. $37.75a = ...m^2$ ។

2. គណនា

ក. $3ha\ 5a\ 27ca + 2ha\ 35a\ 40m^2 = ...m^2$

ខ. $77a\ 35m^2 - 5075m^2 = ...m^2$ ។



www.elibraryofcambodia.org

3. គណនាផ្ទៃក្រឡា

ក.




$A = a \times b$

$= \square \times \square$

$= \square\, cm^2$

ខ.




$A = a \times a$

$= \square \times \square$

$= \square\, cm^2$

គ.




ឃ.




ង.




4. គណនាផ្ទៃក្រឡាផ្នែកឆូត

ក.




ខ.




គ.




ឃ.






www.elibraryofcambodia.org

# ផ្ទៃក្រឡាត្រីកោណ

គណនាផ្ទៃក្រឡាត្រីកោណកែងមួយ ដែលមានរង្វាស់ជ្រុង 3cm និង 4cm ។




ផ្ទៃក្រឡាត្រីកោណស្មើនឹងពាក់កណ្ដាល ផ្ទៃក្រឡាចតុកោណកែង

$A = \frac{1}{2} \times 3 \times 4 = 6cm^2$ ។

គណនាផ្ទៃក្រឡាត្រីកោណដែលមានបាត 4cm និងកម្ពស់ 3cm ។

ផ្ទៃក្រឡាត្រីកោណស្មើនឹងពាក់កណ្ដាល ផ្ទៃក្រឡាចតុកោណកែងដែលមានទទឹង 3cm និង បណ្ដោយ 4cm ។




ដូចនេះ $A = \frac{1}{2} \times 3 \times 4 = 6cm^2$ ។

ជាទូទៅ បើ a ជាបាតនិង h ជាកម្ពស់ត្រីកោណ ហើយ A ជាផ្ទៃក្រឡានោះ ផ្ទៃក្រឡាត្រីកោណកំណត់ដោយ $A = \frac{a \times h}{2}$ ។







ផ្ទៃក្រឡាត្រីកោណ $= \frac{\text{បាត} \times \text{កម្ពស់}}{2}$

$$A = \frac{a \times h}{2}$$



www.elibraryofcambodia.org

## លំហាត់

1. គណនាផ្ទៃក្រឡា

ក.




ខ.




2. គណនាផ្ទៃក្រឡានៃរូបខាងក្រោម

ក.




ខ.




3. ក. គណនាផ្ទៃក្រឡានៃត្រីកោណ ABD

ខ. គណនាផ្ទៃក្រឡានៃត្រីកោណ ACD

គ. ទាញរកផ្ទៃក្រឡានៃត្រីកោណ ABC ។






www.elibraryofcambodia.org

# ផ្ទៃក្រឡានៃប្រលេឡូក្រាម

គណនាផ្ទៃក្រឡាប្រលេឡូក្រាម ដែលមានកម្ពស់ 3cm និងបាត 5cm ។







ផ្ទៃក្រឡាប្រលេឡូក្រាមស្មើនឹងផ្ទៃក្រឡាចតុកោណកែងដែលមានទទឹង 3cm និងបណ្តោយ 5cm ៖ $A = 3\times 5 = 15cm^2$

ដូចនេះ $A = 15cm^2$ ។

ជាទូទៅ បើ a ជាបាតនិង h ជាកម្ពស់ប្រលេឡូក្រាម នោះ ផ្ទៃក្រឡាប្រលេឡូក្រាមកំណត់ដោយ $A = a\times h$ ។




ផ្ទៃក្រឡាប្រលេឡូក្រាម = បាត × កម្ពស់

$$A = a\times h$$

## លំហាត់

គណនាផ្ទៃក្រឡាប្រលេឡូក្រាម ។

ក.




ខ.






www.elibraryofcambodia.org

## ផ្ទៃក្រឡាចតុកោណព្នាយ

គណនាផ្ទៃក្រឡាចតុកោណព្នាយដែលមានបាតតូចស្មើនឹង2m បាតធំស្មើនឹង 5m និងកម្ពស់ស្មើនឹង 3m ។







ផ្ទៃក្រឡាចតុកោណព្នាយស្មើនឹងពាក់កណ្ដាលផ្ទៃក្រឡាប្រលេឡូក្រាមដែលមានកម្ពស់ 3m និងបាតស្មើនឹង (2+5)m :

$$A = \frac{1}{2} \times 3 \times (2+5) = \frac{1}{2} \times 3 \times 7$$

$$A = \frac{21}{2} = 10.5\text{m}^2$$

ដូចនេះ $A = 10.5\text{m}^2$ ។

ជាទូទៅ បើ a ជាបាតតូច b ជាបាតធំ និង h ជាកម្ពស់នៃចតុកោណព្នាយ នោះផ្ទៃក្រឡានៃចតុកោណព្នាយកំណត់ដោយ




$$A = \frac{(a+b) \times h}{2} \text{ ។}$$

$$\text{ផ្ទៃក្រឡាចតុកោណព្នាយ} = \frac{(\text{បាតតូច} + \text{បាតធំ}) \times \text{កម្ពស់}}{2}$$

$$A = \frac{(a+b) \times h}{2}$$

www.elibraryofcambodia.org

## លំហាត់

1. គណនាផ្ទៃក្រឡាចតុកោណព្នាយ ។

ក.




ខ.




2. គេដឹងថាចតុកោណព្នាយមានផ្ទៃក្រឡាស្មើនឹង $8m^2$ ។
ចូររកកម្ពស់ចតុកោណព្នាយនេះ ។




3. ដីស្រែមួយរាងចតុកោណព្នាយដូចរូប ។ រកផលស្រូវដែលប្រមូលបានបើគេដឹងថា ដី $1m^2$ ផ្តល់ផលស្រូវ 0.25kg ។




4. គណនាប្រវែង x

ក.




ខ.






www.elibraryofcambodia.org

# ផ្ទៃក្រឡានៃថាស

ចូររាប់ផ្ទៃក្រឡា ដែលមានក្នុងថាសមួយដែលមានកាំ 3cm ។




គេអាចគណនាផ្ទៃក្រឡាថាសដូចខាងក្រោម ៖

ពុះថាសជា 12 ចំណែកស្មើៗគ្នា រួចផ្គុំចំណែកនោះ បានរូបមួយដែលមានរាងជាប្រលេឡូក្រាមមួយ ។




ប្រលេឡូក្រាមមានកម្ពស់ស្មើនឹង R និងបាតវាមានប្រវែងស្មើនឹង $\pi R$ ត្រូវជាកន្លះបរិមាត្រថាស ។ ដូចនេះផ្ទៃក្រឡាថាសស្មើនឹងផ្ទៃក្រឡាប្រលេឡូក្រាម ។

$A =$ កម្ពស់ $\times$ បាត $= R \times \pi R = \pi R^2$ ព្រោះ $R^2 = R \times R$

$R = 3\text{cm}$ ; $A = 3.14 \times 3 \times 3 = 28.26\text{cm}^2$ ។

ជាទូទៅ បើ R ជាកាំថាសនោះ ផ្ទៃក្រឡាថាសកំណត់ដោយ

$\boxed{A = \pi R^2}$ ។




ផ្ទៃក្រឡាថាស = $\pi \times$ កាំ $\times$ កាំ

$A = \pi R^2$ ; $\pi = 3.14$

www.elibraryofcambodia.org

## លំហាត់

1. គណនាផ្ទៃក្រឡាថាស

ក. ខ. គ.




2. គណនាផ្ទៃក្រឡាឆូត

ក. ខ. គ.




## ចំណោទ

1. គេរៀបរបងថ្មមួយដែលមានប្រវែង 18m និងកម្ពស់ 2.2m ។

   ក. គណនាផ្ទៃក្រឡារបង ។

   ខ. តើគេត្រូវការឥដ្ឋប៉ុន្មានដុំ បើគេដឹងថា $1m^2$ ប្រើឥដ្ឋ 50 ដុំ ?

2. អាងហែលទឹកមួយធ្វើដោយកន្លះថាសពីរនិងចតុកោណកែងមួយដូចរូប ។ ចូរគណនាផ្ទៃក្រឡាបាតអាងទឹកនេះ ។ គេឱ្យ $\pi = \frac{22}{7}$




3. ដំបូលផ្ទះមួយផ្គុំដោយចតុកោណព្នាយនិងត្រីកោណដូចរូប ។ គេប្រក់ក្បឿងអស់ 50 សន្លឹកក្នុង $1m^2$ ។ រកចំនួនក្បឿងទាំងអស់ ។






www.elibraryofcambodia.org

# 8 វិធីគុណនិងវិធីចែកចំនួនទសភាគ

## វិធីគុណចំនួនទសភាគនឹងចំនួនគត់

នំមួយកញ្ចប់មានទម្ងន់ 1.255kg ។ តើនំ 15 កញ្ចប់មានទម្ងន់ប៉ុន្មាន ?

$1.255 \times 15 = \square$

$$\begin{array}{r} {\scriptstyle 1\,2\,2} \\ 1.255 \\ \times \quad 15 \\ \hline 6275 \\ +1255\phantom{0} \\ \hline 18.825 \end{array}$$




ដូចនេះ នំ 15 កញ្ចប់មានទម្ងន់ 18.825kg ។

> វិធីគុណចំនួនទសភាគនឹងចំនួនគត់ត្រូវគុណដូចចំនួនគត់ ។ ផ្នែកទសភាគនៃផលគុណស្មើនឹងផ្នែកទសភាគនៃតួគុណ ។

## លំហាត់

ចូរគណនាផលគុណខាងក្រោម

| | | |
|---|---|---|
| ក. $18.050 \times 12$ | ខ. $25.115 \times 18$ | គ. $33.183 \times 27$ |
| ឃ. $135.205 \times 43$ | ង. $192.480 \times 56$ | ច. $215.178 \times 62$ |
| ឆ. $285.312 \times 65$ | ជ. $308.095 \times 73$ | ឈ. $346.856 \times 78$ |
| ញ. $15.450 \times 18$ | ដ. $23.750 \times 25$ | ឋ. $35.135 \times 45$ |
| ឌ. $61.21 \times 750$ | ឍ. $85 \times 170.554$ | ណ. $92 \times 153.425$ ។ |

www.elibraryofcambodia.org

## វិធីគុណចំនួនទសភាគនឹងចំនួនទសភាគ

ផ្ទះល្វែងមួយមានបណ្តោយ 8.25m និងទទឹង 3.8m ។ តើផ្ទះល្វែងនោះមានផ្ទៃក្រឡាប៉ុន្មានម៉ែត្រការេ ?

$8.25 \times 3.8 = \square$




ដូចនេះ ផ្ទះល្វែងនោះមានផ្ទៃក្រឡា $31.35m^2$ ។

> វិធីគុណចំនួនទសភាគនឹងចំនួនទសភាគ ត្រូវគុណដូចចំនួនគត់ ។ ផ្នែកទសភាគនៅផលគុណស្មើនឹងផ្នែកទសភាគនៃតួគុណទី 1 បូកនឹងផ្នែកទសភាគនៃតួគុណទី 2 ។

## លំហាត់

ចូរធ្វើប្រមាណវិធីខាងក្រោម

| | | |
|---|---|---|
| ក. $16.25 \times 5.3$ | ខ. $22.86 \times 0.7$ | គ. $0.56 \times 31.9$ |
| ឃ. $28.08 \times 7.5$ | ង. $0.18 \times 25.8$ | ច. $47.06 \times 10.5$ |
| ឆ. $56.73 \times 17.7$ | ជ. $69.05 \times 15.5$ | ឈ. $73.3 \times 21.35$ |
| ញ. $23.08 \times 0.50$ | ដ. $98.5 \times 2.25$ | ឋ. $25.5 \times 25.50$ |
| ឌ. $58.8 \times 47.45$ | ឍ. $10.95 \times 5.80$ | ណ. $15.05 \times 82.8$ ។ |



www.elibraryofcambodia.org

## ការប៉ាន់ស្មានផលគុណចំនួនទសភាគ

សួនច្បារមួយរាងចតុកោណកែងមានបណ្តោយប្រវែង 10.8m និងទទឹង 5.25m ។ តើសួនច្បារនោះមានផ្ទៃក្រឡាប្រហែលប៉ុន្មាន ?

$10.8 \times 5.25 = \square$

$$\begin{array}{r} 10.8 \\ \times \quad 5.25 \\ \hline \end{array} \quad \xrightarrow{\text{បង្គត់ទៅ}} \quad \begin{array}{r} 11 \\ \times \quad 5 \\ \hline 55 \end{array}$$



ដូចនេះ សួនច្បារនោះមានផ្ទៃក្រឡាប្រហែល $55m^2$ ។

ដើម្បីប៉ាន់ស្មានផលគុណចំនួនទសភាគ យើងត្រូវបង្គត់ចំនួនទសភាគនៅតួគុណឱ្យទៅជាចំនួនគត់រួចធ្វើប្រមាណវិធីគុណ ។

សំគាល់ : ប្រសិនបើតួគុណណាមួយបង្គត់បានសូន្យ គេមិនធ្វើការប៉ាន់ស្មានទេ ។

## លំហាត់

ចូរប៉ាន់ស្មានផលគុណខាងក្រោម

| | | | | | |
|---|---|---|---|---|---|
| ក. | 18.05 × 9.7 | ខ. | 0.95 × 8.6 | គ. | 25.8 × 15.25 |
| ឃ. | 30.3 × 15.75 | ង. | 38.21 × 23.8 | ច. | 45.65 × 25.9 |
| ឆ. | 50.86 × 30.3 | ជ. | 68.05 × 25.8 | ឈ. | 72.15 × 35.2 |
| ញ. | 78.15 × 38.7 | ដ. | 81.03 × 42.8 | ឋ. | 83.90 × 40.7 |
| ឌ. | 48.89 × 16.7 | ឍ. | 62.15 × 15.80 | ណ. | 68.09 × 16.2 |
| ត. | 75.47 × 67.9 | ថ. | 59.46 × 42.73 | ទ. | 71.45 × 24.9 ។ |



www.elibraryofcambodia.org

## ចំណោទ

1. ជាងកាត់ដេរម្នាក់ប្រើកំណាត់សំពត់អស់ 1.25m សម្រាប់កាត់ខោមួយ ។ បើគាត់កាត់ខោ 15 តើគាត់ត្រូវប្រើកំណាត់សំពត់អស់ប៉ុន្មាន ?

2. ជាងម្នាក់ទិញស៊ីម៉ងត៍ 5 បាវដោយក្នុង 1 បាវមានទម្ងន់ 50kg ។ គាត់យកស៊ីម៉ងត៍នោះទៅធ្វើពាងទឹកបានពាង 12 ។ ក្នុងពាងមួយគាត់ប្រើស៊ីម៉ងត៍អស់ 20.25kg ។ តើជាងនោះនៅសល់ស៊ីម៉ងត៍ប៉ុន្មានគីឡូក្រាមទៀត ?

3. សុខយកប្រាក់ដុល្លារអាមេរិក 127 $ ទៅដូរយកដុល្លារសិង្ហបុរី ។ បើអត្រាប្តូរប្រាក់កំណត់ 1 $ អាមេរិកដូរបាន 1.38 $ សិង្ហបុរី ។ តើសុខដូរបានប្រាក់ប៉ុន្មាន ?

4. គណនាបរិមាត្ររង្វង់ ដែលមានកាំ 1.25m ។




5. គណនាផលបូកបរិមាត្ររង្វង់ទាំងពីររួចប្រៀបធៀបផលបូកនេះទៅនឹងបរិមាត្រចតុកោណកែង ។




6. បូណាទិញសាច់គោចៀន 2.5kg រួចវេចខ្ចប់ដាក់ក្នុងប្រអប់ដែលមានទម្ងន់ 0.34kg ហើយយកទៅផ្ញើឱ្យបងរៀននៅបរទេស ។ តើបូណាត្រូវបង់ថ្លៃផ្ញើប៉ុន្មាន បើ 1kg ត្រូវបង់ថ្លៃ 6 $ ?

7. ចម្ការមួយមានរាងចតុកោណកែង ទទឹងមានប្រវែង 35.25m និងបណ្តោយវែងជាងទទឹង 4 ដង ។ គេលក់ដីចម្ការនោះថ្លៃ 5.8 $ ក្នុង $1m^2$ ។ តើចម្ការនោះលក់បានថ្លៃប៉ុន្មានដុល្លារ ?



www.elibraryofcambodia.org

## វិធីចែកចំនួនទសភាគនឹងចំនួនគត់

55.75 ÷ 5 = □

**របៀបទី 1**

```
  55.75 | 5
 - 5    |11.15
   05
 -  5
    07
 -   5
     25
 -   25
     00
```

**របៀបទី 2**

```
  5575 | 500
 - 500 |11.15
  0575
 - 500
    750
 -  500
   2500
 - 2500
   0000
```

ដូចនេះ 55.75 ÷ 5 = 11.15 ។

យើងអាចចែកចំនួនទសភាគនឹងចំនួនគត់បានពីររបៀប

- របៀបទី 1 : ចែកផ្នែកគត់មុន បន្ទាប់មកចែកផ្នែកទសភាគ ។
- របៀបទី 2 : ធ្វើតំណាងចែកឱ្យទៅជាចំនួនគត់ដោយគុណតំណាងចែកនិងតួចែកនឹង 10 កាលណាតំណាងចែកមានផ្នែកទសភាគមួយខ្ទង់ ។ គុណនឹង 100 កាលណាតំណាងចែកមានផ្នែកទសភាគពីរខ្ទង់ ។ គុណនឹង 1000 កាលណាតំណាងចែកមានផ្នែកទសភាគបីខ្ទង់ រួចធ្វើប្រមាណវិធីចែក ។

## លំហាត់

ចូរគណនាផលចែកដោយយកផ្នែកទសភាគត្រឹមខ្ទង់ភាគពាន់

ក. 12.23 ÷ 6 ខ. 16.64 ÷ 8 គ. 25.15 ÷ 12 ឃ. 22.135 ÷ 4

ង. 25.25 ÷ 4 ច. 45.125 ÷ 5 ឆ. 18.456 ÷ 9 ជ. 50.25 ÷ 25 ។



www.elibraryofcambodia.org

# វិធីចែកចំនួនគត់នឹងចំនួនទសភាគ

ទីធ្លារាងចតុកោណកែងមួយមានផ្ទៃក្រឡា $620m^2$ ។ ទទឹងមានប្រវែង 15.5m ។ រកប្រវែងបណ្ដោយទីធ្លានោះ ។

$620 \div 15.5 = \square$

```
  6200 | 155
 -620  |-----
 ----  | 40
   00
  - 0
  ---
    0
```




ដូចនេះ ទីធ្លានោះមានបណ្ដោយប្រវែង 40m ។

ដើម្បីចែកចំនួនគត់នឹងចំនួនទសភាគយើងត្រូវធ្វើតួចែកឱ្យទៅជាចំនួនគត់ដោយគុណតំណាងចែកនិងតួចែកនឹង

- 10 កាលណាតួចែកមានផ្នែកទសភាគមួយខ្ទង់
- 100 កាលណាតួចែកមានផ្នែកទសភាគពីរខ្ទង់
- 1000 កាលណាតួចែកមានផ្នែកទសភាគបីខ្ទង់ ។

## លំហាត់

ចូរធ្វើប្រមាណវិធីខាងក្រោមដោយយកផលចែកត្រឹមខ្ទង់ភាគពាន់

| | | |
|---|---|---|
| ក. $18 \div 2.5$ | ខ. $12 \div 0.5$ | គ. $25 \div 0.25$ |
| ឃ. $70 \div 0.5$ | ង. $260 \div 1.3$ | ច. $15 \div 4.15$ |
| ឆ. $20 \div 8.5$ | ជ. $26 \div 3.14$ | ឈ. $35 \div 0.18$ |
| ញ. $125 \div 5.25$ | ដ. $255 \div 6.15$ | ឋ. $385 \div 15.5$ |
| ឌ. $505 \div 0.85$ | ឍ. $620 \div 8.5$ | ណ. $650 \div 25.5$ |
| ត. $548 \div 18.2$ | ថ. $710 \div 50.2$ | ទ. $852 \div 16.5$ ។ |



www.elibraryofcambodia.org

## វិធីចែកចំនួនទសភាគនឹងចំនួនទសភាគ

ដីឡូត៍រាងចតុកោណកែងមួយមានផ្ទៃក្រឡា $96.6m^2$ ។ ទទឹងមានប្រវែង 5.25m ។រកប្រវែងបណ្ដោយដីឡូត៍នោះ ។

$96.6 \div 5.25 = \square$

```
  96.60 | 5.25
- 525   | 18.4
  4410
- 4200
  02100
-  2100
      0
```

96.6 = 96.60



ដូចនេះ បណ្ដោយដីឡូត៍នោះមានប្រវែង 18.4m ។

ដើម្បីចែកចំនួនទសភាគនឹងចំនួនទសភាគ យើងត្រូវ

1. ធ្វើផ្នែកទសភាគនៃតំណាងចែក និងតួចែកឱ្យមានចំនួនខ្ទង់ស្មើគ្នា ។
2. លុបចំណុចទសភាគរួចធ្វើប្រមាណវិធីចែកដូចចែកចំនួនគត់ដែរ ។

## លំហាត់

ចូរធ្វើប្រមាណវិធីខាងក្រោមដោយយកផលចែកត្រឹមខ្ទង់ភាគពាន់

| | | |
|---|---|---|
| ក. $10.5 \div 1.5$ | ខ. $1.84 \div 0.23$ | គ. $25.8 \div 4.5$ |
| ឃ. $31.2 \div 0.52$ | ង. $45.24 \div 6.7$ | ច. $32.5 \div 0.04$ |
| ឆ. $22.08 \div 9.6$ | ជ. $150.5 \div 0.25$ | ឈ. $263.7 \div 0.25$ |
| ញ. $17.24 \div 0.02$ | ដ. $350.15 \div 8.5$ | ឋ. $545.5 \div 0.25$ |
| ឌ. $550.5 \div 15.7$ | ឍ. $460.5 \div 0.46$ | ណ. $572.8 \div 0.26$ |
| ត. $0.945 \div 0.05$ | ថ. $0.872 \div 0.75$ | ទ. $0.876 \div 1.85$ ។ |



www.elibraryofcambodia.org

# ការប៉ាន់ស្មានផលចែកចំនួនទសភាគ

រង្វង់មួយមានបរិមាត្រ 43.12m ។តើអង្កត់ផ្ចិតនៃរង្វង់នោះមានប្រវែងប្រហែលប៉ុន្មាន ?

43.12 ÷ 3.14 = □

```
  43 | 3
 - 3 | 14.3
 ----
  13
 -12
 ----
   10
 -  9
 ----
    1
```




ដូចនេះ អង្កត់ផ្ចិតនៃរង្វង់មានប្រវែងប្រហែល 14m ។

> ដើម្បីប៉ាន់ស្មានផលចែកចំនួនទសភាគ យើងត្រូវបង្គត់ចំនួនទសភាគនៅតំណាងចែកនិងតួចែកទៅជាចំនួនគត់ រួចធ្វើប្រមាណវិធីចែក ។ បើផលចែកជាចំនួនទសភាគត្រូវបង្គត់ផលចែកនោះជាចំនួនគត់ ។

**សំគាល់:** ប្រសិនបើតំណាងចែក ឬតួចែកបង្គត់បានសូន្យ គេមិនប៉ាន់ស្មានទេ ។

## លំហាត់

ចូរប៉ាន់ស្មានផលចែក

| | | |
|---|---|---|
| ក. 15.35 ÷ 0.85 | ខ. 22.5 ÷ 5.25 | គ. 45.2 ÷ 12.7 |
| ឃ. 53.95 ÷ 16.3 | ង. 72.2 ÷ 21.8 | ច. 120.8 ÷ 25.3 |
| ឆ. 185.50 ÷ 38.9 | ជ. 240.5 ÷ 41.35 | ឈ. 265.35 ÷ 45.25 |
| ញ. 360.40 ÷ 52.80 | ដ. 424.75 ÷ 50.05 | ឋ. 485.3 ÷ 55.85 |
| ឌ. 572.60 ÷ 58.17 | ឍ. 575.85 ÷ 60.15 | ណ. 605.38 ÷ 65.8 |
| ត. 615.50 ÷ 85.12 | ថ. 680.9 ÷ 92.15 | ទ. 765.15 ÷ 95.15 |
| ធ. 786.8 ÷ 88.15 | ន. 809.3 ÷ 96.68 | ប. 965.65 ÷ 98.90 ។ |



បោះពុម្ពផ្សាយ ឆ្នាំ ២០០៦ PDH

www.elibraryofcambodia.org

## ការប្រើប្រាស់ម៉ាស៊ីនគិតលេខលើប្រមាណវិធីចំនួនទសភាគ

ឧទាហរណ៍ ៖ គណនា 185.65 ÷ 23.5 =

វិធីប្រើ ៖ មុនដំបូងត្រូវចុចសញ្ញា " ON/C " ដើម្បីឱ្យម៉ាស៊ីនដំណើរការ ។

បន្ទាប់មកចុច ៖ [1] [8] [5] [.] [6] [5] [÷] [2] [3] [.] [5] [=]



លេខ 7.9 បង្ហាញលើកញ្ចក់ម៉ាស៊ីនគិតលេខ គឺជាផលចែក ។ បន្ទាប់ពីប្រើប្រាស់រួចត្រូវចុចសញ្ញា " OFF " ដើម្បីបិទម៉ាស៊ីន ។

បើរកផលបូក ផលដក ផលគុណនិងផលចែកចំនួនទសភាគត្រូវអនុវត្តដូចលំនាំខាងលើដោយគ្រាន់តែប្តូរសញ្ញា "+" សញ្ញា " − " សញ្ញា " × " ឬសញ្ញា " ÷ " ។

## លំហាត់

ចូរធ្វើប្រមាណវិធីខាងក្រោមដោយយកផលចែកត្រឹមខ្ទង់ភាគពាន់

| | | | |
|---|---|---|---|
| ក. | 2510.25 + 18.50 | ខ. | 2837 + 180.315 |
| គ. | 3042.315 + 23.45 | ឃ. | 4206.405 + 256 |
| ង. | 5015.108 + 4215.12 | ច. | 6821.510 + 3250.555 |
| ឆ. | 310.115 − 156 | ជ. | 421.05 − 250 |
| ឈ. | 455 − 325.50 | ញ. | 1850 − 585.752 |
| ដ. | 3410 − 2810.265 | ឋ. | 3856.215 − 315 |
| ឌ. | 4685.505 − 289 | ឍ. | 521.875 − 392.915 |
| ណ. | 20.55 × 15 | ត. | 851 × 25.75 |
| ថ. | 52.85 ÷ 15 | ទ. | 135.25 ÷ 35.5 ។ |

 www.elibraryofcambodia.org

## ចំណោទ

1. ប្រធានភូមិម្នាក់ចែកស្រូវពូជ 243.2kg ឱ្យកសិករ 16 គ្រួសារស្មើៗគ្នា ។ តើក្នុងមួយគ្រួសារទទួលបានស្រូវពូជប៉ុន្មាន ?
2. ប្រេងកាត 4.5ℓ មានទម្ងន់ 3.42kg ។ តើប្រេង 25ℓ មានទម្ងន់ប៉ុន្មាន ?
3. ពូលីមានទឹកត្រី 2 ធុង ។ ធុងទី 1 មានទឹកត្រី 21ℓ ធុងទី 2 មានទឹកត្រី 15ℓ ។ គាត់យកទឹកត្រីទាំង 2 ធុងច្រកចូលក្នុងដបដែលមានចំណុះ 0.75ℓ ។ តើគាត់ច្រកទឹកត្រីទាំងអស់បានប៉ុន្មានដប ? បើគាត់លក់ទឹកត្រីក្នុង 1 ដបថ្លៃ 1500 ៛ ។ តើគាត់លក់ទឹកត្រីទាំងអស់បានប៉ុន្មានរៀល ?
4. រង្វង់មួយមានបរិមាត្រ 13.188m រកកាំរង្វង់នេះ ។
5. ជាងដេរម្នាក់ទិញកំណាត់សំពត់ 134.5m អស់ប្រាក់ 250 ដុល្លារ ។ គាត់ដឹងថាក្នុងខោអាវមួយសម្រាប់ត្រូវការកំណាត់សំពត់ 2.8m ។ គាត់លក់ខោអាវទាំងអស់បានប្រាក់ 322.5 ដុល្លារ ។

   ក. តើកំណាត់សំពត់ទាំងអស់គាត់កាត់ខោអាវបានប៉ុន្មានសម្រាប់ ?

   ខ. តើខោអាវមួយសម្រាប់ចំណេញបានប្រាក់ប៉ុន្មាន ?
6. បូណាលោតកម្ពស់ 3 លើក លើកទី 1 លោតបាន 1.63m លើកទី 2 បាន 1.61m ហើយនៅលើកទី 3 លោតបាន 1.65m ។ រកកម្ពស់ដែលបូណាលោតបានពិតជាមធ្យម ។
7. ដីមួយកន្លែងមានរាងចតុកោណកែង ។ ទទឹងមានប្រវែង 12.5m ហើយមានផ្ទៃក្រឡាស្មើនឹងផ្ទៃក្រឡាដីរាងការេ ដែលមានជ្រុង 25m ។ គណនាបរិមាត្រដីរាងចតុកោណកែង ។
8. ដីមួយកន្លែងមានរាងចតុកោណកែង ។ បណ្ដោយមានប្រវែង 35.5m ទទឹងមានប្រវែង 25.25m ។ គេធ្វើរបងជុំវិញដីនោះដោយទុកច្រកទ្វារចូល 3.2m ។ គេចំណាយលើថ្លៃសាងសង់អស់ 650 ដុល្លារ ។ តើក្នុងរបង 1m ត្រូវចំណាយអស់ប៉ុន្មាន ?



www.elibraryofcambodia.org

# 9 តួចែករួមធំបំផុត-ពហុគុណរួមតូចបំផុត

## កត្តានៃមួយចំនួន

$15 = 1 \times 15$ ឬ $15 = 3 \times 5$

15 ចែកដាច់នឹង 1 ; 3 ; 5 និង 15 ។ 1 ; 3 ; 5 និង 15 ជាកត្តានៃ 15 ។

$21 = 1 \times 21$ ឬ $21 = 7 \times 3$ ។

21 ចែកដាច់នឹង 1 ; 3 ; 7 និង 21 ។ 1 ; 3 ; 7 និង 21 ជាកត្តានៃ 21 ។

22 ចែកមិនដាច់នឹង 3 ; 5 ; 7... ។ 3 ; 5 ; 7... មិនមែនជាកត្តានៃ 22 ទេ ។

51 ចែកមិនដាច់នឹង 2 ; 4 ; 5... ។ 2 ; 4 ; 5... មិនមែនជាកត្តានៃ 51 ទេ ។

> កត្តានៃមួយចំនួនគឺជាតួចែកដាច់នៃចំនួននោះ ។

## លំហាត់

1. ចូរឆ្លើយសំណួរខាងក្រោម

ក. 5 ជាកត្តានៃ 35 ឬទេ ? ព្រោះអ្វី ?

ខ. 8 ជាកត្តានៃ 58 ឬទេ ? ព្រោះអ្វី ?

គ. 17 ជាកត្តានៃ 156 ឬទេ ? ព្រោះអ្វី ?

2. ចូរសរសេរចំនួនខាងក្រោមជាផលគុណកត្តាតាមគំរូ

$16 = 8 \times 2$ ឬ $16 = 4 \times 4$ ឬ $16 = 1 \times 16$

ក. 24 ខ. 30 គ. 45 ឃ. 48 ង. 62 ។

3. ចូររកកត្តាទាំងអស់នៃចំនួនខាងក្រោម

ក. 10 ខ. 18 គ. 21 ឃ. 29 ង. 31 ។

www.elibraryofcambodia.org

## ចំនួនបឋម

2 មានកត្តា 1 និង 2 ។

3 មានកត្តា 1 និង 3 ។

4 មានកត្តា 1 ; 2 ; និង 4 ។

5 មានកត្តា 1 និង 5 ។

6 មានកត្តា 1 ; 2 ; 3 និង 6 ។

7 មានកត្តា 1 និង 7 ។

11 មានកត្តា 1 និង 11 ។

12 មានកត្តា 1 ; 2 ; 3 ; 4 ; 6 និង 12 ។

ចំនួន 2 ; 3 ; 5 ; 7 និង 11 ជាចំនួនបឋម ។

ចំនួន 4 ; 6 ; 12 ជាចំនួនមិនបឋម ។

> ចំនួនបឋមជាចំនួនគត់ធំជាង 1 ហើយមានកត្តាតែពីរគត់គឺ 1 និងខ្លួនឯង ។
> ចំនួនមិនបឋមជាចំនួនធំជាង 1 ហើយមានកត្តាលើសពីពីរ ។

## លំហាត់

1. ចូររកចំនួនបឋមទាំងអស់

   ក. ចំនួនពី 1 ដល់ 20      ខ. ចំនួនពី 20 ដល់ 50 ។

2. ចូរគូសបន្ទាត់ពីក្រោមចំនួនបឋម

| | | | | |
|---|---|---|---|---|
| ក. 5 | ខ. 6 | គ. 8 | ឃ. 11 | ង. 67 |
| ច. 69 | ឆ. 71 | ជ. 91 | ឈ. 125 | ញ. 261 |
| ដ. 357 | ឋ. 369 | ឌ. 373 | ឍ. 381 | ណ. 450 ។ |

3. ចូររកចំនួនបឋមឱ្យបាន 2 និងចំនួនមិនបឋមឱ្យបាន 2 ក្រៅពីចំនួនបឋមនិងចំនួនមិនបឋមដែលមាននៅសំណួរខាងលើ ។



www.elibraryofcambodia.org

# ការសរសេរមួយចំនួនជាផលគុណកត្តាបឋម

សរសេរចំនួន 24 ជាផលគុណកត្តាបឋម

ក. វិធីគុណ




ខ. វិធីចែក

| | | |
|---|---|---|
| 24 | 2 | 24 ចែកនឹង 2 បាន 12 |
| 12 | 2 | 12 ចែកនឹង 2 បាន 6 |
| 6 | 2 | 6 ចែកនឹង 2 បាន 3 |
| 3 | 3 | 3 ចែកនឹង 3 បាន 1 |
| 1 | | |

ដូចនេះ ផលគុណកត្តាបឋមនៃ 24 គឺ $2 \times 2 \times 2 \times 3$ ។

ដោយ 2 និង 3 ជាចំនួនបឋម វាជាកត្តាបឋមនៃ 24 ។

យើងអាចសរសេរមួយចំនួនជាផលគុណកត្តាបឋមតាមវិធីគុណ ឬវិធីចែក ។

## លំហាត់

1. ចូរបំពេញ □ ខាងក្រោម

ក.




15 = 5 × □

ខ.




36 = □ × □ × □ × □

គ.

| | |
|---|---|
| 45 | 3 |
| 15 | □ |
| □ | □ |
| □ | |

45 = □ × □ × □

ឃ.

| | |
|---|---|
| 54 | 2 |
| 27 | □ |
| □ | □ |
| □ | □ |
| □ | |

54 = □ × □ × □ × □

2. ចូរសរសេរចំនួនខាងក្រោមជាផលគុណកត្តាបឋម

ក. 8 ខ. 16 គ. 21 ឃ. 27 ង. 39 ច. 42

ឆ. 56 ជ. 77 ឈ. 125 ញ. 105 ដ. 204 ឋ. 255

ឌ. 350 ឍ. 355 ណ. 396 ត. 412 ថ. 420 ទ. 450 ។

www.elibraryofcambodia.org

## តួចែករួមធំបំផុត

ក. រកតួចែករួមធំបំផុតនៃ 18 និង 24

តួចែកដាច់នៃ 18 មាន : 1 ; 2 ; 3 ; 6 ; 9 ; 18 ។

តួចែកដាច់នៃ 24 មាន : 1 ; 2 ; 3 ; 4 ; 6 ; 8 ; 12 ; 24 ។

18 និង 24 មានតួចែកដាច់រួម ៖ 1 ; 2 ; 3 និង 6 ។

តួចែករួមធំបំផុតនៃ 18 និង 24 គឺ 6 ។

គេសរសេរ ត (18;24) = 6 ។

ខ. រកតួចែករួមធំបំផុតនៃ 16 ; 32 និង 40

តួចែកដាច់នៃ 16 មាន ៖ 1 ; 2 ; 4 ; 8 ; 16 ។

តួចែកដាច់នៃ 32 មាន ៖ 1 ; 2 ; 4 ; 8 ; 16 ; 32 ។

តួចែកដាច់នៃ 40 មាន ៖ 1 ; 2 ; 4 ; 5 ; 8 ; 20 ; 40 ។

16 ; 32 និង 40 មានតួចែករួម : 1 ; 2 ; 4 និង 8 ។

តួចែករួមធំបំផុតនៃ 16 ; 32 និង 40 គឺ 8 ។

គេសរសេរ ត (16;32;40) = 8 ។

តួចែករួមធំបំផុតនៃពីរ ឬច្រើនចំនួន គឺជាតួចែករួមមានតម្លៃធំជាងគេ ។

## លំហាត់

ចូររកតួចែករួមធំបំផុតនៃចំនួនខាងក្រោម

| | | |
|---|---|---|
| ក. ត ( 2 ; 4 ) | ខ. ត ( 3 ; 6 ) | គ. ត ( 4 ; 6 ) |
| ឃ. ត ( 6 ; 10 ) | ង. ត ( 6 ; 12 ) | ច. ត ( 7 ; 14 ) |
| ឆ. ត ( 8 ; 16; 32 ) | ជ. ត ( 5 ; 20 ; 30 ) | ឈ. ត ( 10 ; 20 ; 40 ) |
| ញ. ត ( 2 ; 4; 6 ) | ដ. ត ( 3 ; 9 ; 12 ) | ឋ. ត ( 4 ; 8 ; 12 ) ។ |



www.elibraryofcambodia.org

## របៀបរកតួចែករួមធំបំផុតតាមផលគុណកត្តាបឋម

ក. រក ត (18 ; 30)

$18 = 2 \times 3 \times 3$
$30 = 2 \times 3 \times 5$

កត្តាបឋមរួមនៃ 18 និង 30 គឺ 2 និង 3 ។
តួចែករួមធំបំផុតនៃ 18 និង 30 គឺ $2 \times 3 = 6$
ឬ ត (18 ; 30) = 6 ។

ខ. គណនា ត (6;9;12)

$6 = 2 \times 3$
$9 = 3 \times 3$
$12 = 2 \times 3 \times 2$

កត្តាបឋមរួមនៃ 6 ; 9 និង12 គឺ 3 ។
ឬ ត (6;9;12) = 3 ។

ដើម្បីរកតួចែករួមធំបំផុតនៃពីរ ឬច្រើនចំនួន យើងត្រូវ
1. បំបែកចំនួនទាំងនោះជាផលគុណកត្តាបឋម ។
2. ជ្រើសរើសកត្តាបឋមរួម ។
3. យកកត្តាបឋមរួមគុណគ្នា ឬយកកត្តាបឋមរួម បើមានកត្តាបឋមរួមតែមួយ ។

## លំហាត់

1. ចូរបំពេញ □ ខាងក្រោម

ក. $12 = 2 \times \square \times \square$
$18 = 2 \times \square \times \square$
ត (12;18) = □

ខ. $15 = \square \times \square$
$35 = \square \times \square$
ត (15;35) = □ ។

2. ចូររកតួចែករួមធំបំផុត

ក. ត (6;12) ខ. ត (10;12) គ. ត (12;27)
ឃ. ត (12;36;48) ង. ត (30;50;210) ច. ត (12;36;120) ។

www.elibraryofcambodia.org

## ពហុគុណនៃមួយចំនួន

ក. រកពហុគុណនៃ 2

ពហុគុណនៃ 2 មាន 2 ; 4 ; 6 ; 8 ; 10 ; 12 ; . . .

$2 = 2 \times 1$　　$8 = 2 \times 4$

$4 = 2 \times 2$　　$10 = 2 \times 5$

$6 = 2 \times 3$　　................

ពហុគុណនៃ 2 គឺ 2 គុណនឹងចំនួនគត់មិនសូន្យ ។

ខ. រកពហុគុណនៃ 5

ពហុគុណនៃ 5 មាន 5 ; 10 ; 15 ; 20 ; 25 ; 30 ; . . .

$5 = 5 \times 1$　　$20 = 5 \times 4$

$10 = 5 \times 2$　　$25 = 5 \times 5$

$15 = 5 \times 3$　　............

ពហុគុណនៃ 5 គឺ 5 គុណនឹងចំនួនគត់មិនសូន្យ ។

> ពហុគុណនៃមួយចំនួនគឺ ផលគុណចំនួននោះនឹងចំនួនគត់មិនសូន្យ ។

## លំហាត់

1. ចូររក 5 តួដំបូងជាពហុគុណនៃចំនួនខាងក្រោម

ក. 3　ខ. 4　គ. 5　ឃ. 8　ង. 11

ច. 15　ឆ. 14　ជ. 18　ឈ. 20　ញ. 25 ។

2. តើចំនួនខាងក្រោមជាពហុគុណនៃចំនួនណាខ្លះ ?

ក. 4　ខ. 6　គ. 8　ឃ. 12　ង. 14 ។

ច. 15　ឆ. 18　ជ. 21　ឈ. 22　ញ. 24 ។



www.elibraryofcambodia.org

## ពហុគុណរួមតូចបំផុត

ក. ពហុគុណរួមតូចបំផុតនៃ 4 និង 6

ពហុគុណនៃ 4 មាន 4 ; 8 ; [12] ; 16 ; 20 ; [24] ; 28 ; 32 ; [36] ; ...

ពហុគុណនៃ 6 មាន 6 ; [12] ; 18 ; [24] ; 30 ; [36] ; 42 ; ...

ពហុគុណរួមនៃ 4 និង 6 មាន 12 ; 24 ; 36 ; ...

ពហុគុណរួមតូចបំផុតនៃ 4 និង 6 គឺ 12 ។

គេសរសេរ ព (4; 6) = 12 ។

ខ. ពហុគុណរួមតូចបំផុតនៃ 2 ; 3 និង 4

ពហុគុណនៃ 2 មាន 2 ; 4 ; 6 ; 8 ; 10 ; [12] ; 14 ; ... 22 ; [24] ; ...

ពហុគុណនៃ 3 មាន 3 ; 6 ; 9 ; [12] ; 15 ; 18 ; 21 ; [24] ; 27 ; ...

ពហុគុណនៃ 4 មាន 4 ; 8 ; [12] ; 16 ; 20 ; [24] ; 28 ; 32 ; ...

ពហុគុណរួមនៃ 2 ; 3 និង 4 មាន 12 ; 24 ; ... ។

ពហុគុណរួមតូចបំផុតនៃ 2 ; 3 និង 4 គឺ 12 ។

គេសរសេរ ព (2; 3; 4) = 12

ពហុគុណរួមតូចបំផុត គឺជាពហុគុណរួមដែលមានតម្លៃតូចជាងគេ ។

## លំហាត់

ចូររកពហុគុណរួមតូចបំផុតនៃចំនួនខាងក្រោម

| | | |
|---|---|---|
| ក. ព (2;3) | ខ. ព (2;4) | គ. ព (3;4) |
| ឃ. ព (5;10) | ង. ព (4;8) | ច. ព (6;12) |
| ឆ. ព (2;4;8) | ជ. ព (3;6;9) | ឈ. ព (2;4;5) |
| ញ. ព (6;8;12) | ដ. ព (3;8;12) | ឋ. ព (5;10;15) ។ |

www.elibraryofcambodia.org

## របៀបរកពហុគុណរួមតូចបំផុតតាមផលគុណកត្តាបឋម

ក. រក ព (8;12)

$$8 = 2 \times 2 \times 2$$
$$12 = 2 \times 2 \times 3$$
$$2 \times 2 \times 3 \times 2 = 24$$

ដូចនេះ ព (8;12) = 24 ។

ខ. រក ព (6;12;36)

$$6 = 2 \times 3$$
$$12 = 2 \times 3 \times 2$$
$$36 = 2 \times 3 \times 2 \times 3$$
$$2 \times 3 \times 2 \times 3 = 36$$

ដូចនេះ ព (6;12;36) = 36 ។

ដើម្បីរកពហុគុណរួមតូចបំផុតនៃពីរ ឬច្រើនចំនួន យើងត្រូវ

1. បំបែកចំនួនទាំងនោះជាផលគុណកត្តាបឋម ។
2. ជ្រើសរើសកត្តាបឋមរួម ។
3. គុណកត្តាបឋមរួមនិងកត្តាបឋមមិនរួម ។

## លំហាត់

**1.** ចូរបំពេញ □ ខាងក្រោម

ក. 6 = 2 × □
8 = 2 × □ × □
ព (6;8) = □

ខ. 12 = □ × □ × □
15 = □ × □
ព (12;15) = □ ។

**2.** ចូររកពហុគុណរួមតូចបំផុតនៃចំនួនខាងក្រោម

| | | |
|---|---|---|
| ក. ព (6;8) | ខ. ព (9;12) | គ. ព (9;15) |
| ឃ. ព (15;21) | ង. ព (10;30) | ច. ព (15;45) |
| ឆ. ព (4;6;12) | ជ. ព (3;5;7) | ឈ. ព (9;15;45) |
| ញ. ព (8;16;24) | ដ. ព (4;12;18) | ឋ. ព (9;12;27) |
| ឌ. ព (12;18;24) | ឍ. ព (15;45;60) | ណ. ព (20;50;75) ។ |



www.elibraryofcambodia.org

## ចំណោទ

1. វណ្ណាមានអាយុស្មើនឹងផលបូកបួនតួដំបូងនៃចំនួនបឋម ។ តើវណ្ណាមានអាយុប៉ុន្មានឆ្នាំ ?
2. រស្មីជាប្អូនស្រីរបស់សុខា ។ អាយុរបស់អ្នកទាំងពីរជាកត្តាបឋមនៃ 55 ។ តើរស្មីមានអាយុប៉ុន្មានឆ្នាំ ? សុខាមានអាយុប៉ុន្មានឆ្នាំ ?
3. វីរៈទិញអាវមួយមានតម្លៃស្មើនឹងផលបូក 7 តួដំបូងនៃចំនួនបឋមគុណនឹង 100 ។ តើអាវរបស់វីរៈមានតម្លៃប៉ុន្មានរៀល ?
4. សហគ្រាសមួយមានកម្មករប្រុស 48 នាក់ និងស្រី 72 នាក់ ។ កម្មករទាំងនោះត្រូវបានបង្កើតជាក្រុមតូចៗដើម្បីជួសជុលផ្លូវថ្នល់មួយកន្លែង ដែលក្រុមនីមួយៗចំនួនកម្មករប្រុសនិងស្រីសមាមាត្រគ្នា ។ តើគេបង្កើតជាក្រុមតូចៗច្រើនបំផុតបានប៉ុន្មានក្រុម?
5. ប៊ិកមួយដើមថ្លៃ 1200 ៛ ហើយសៀវភៅមួយក្បាលថ្លៃ 1500 ៛ បូណាចង់ឱ្យការទិញប៊ិក និងសៀវភៅចំណាយប្រាក់ស្មើគ្នាហើយត្រូវអស់ប្រាក់តិចបំផុត ។ តើបូណាត្រូវទិញប៊ិកប៉ុន្មាននិងសៀវភៅប៉ុន្មាន ?
6. គេមានប៊ិក 24 ដើម និងសៀវភៅ 18 ក្បាល ។ គេយកប៊ិក និងសៀវភៅទាំងនេះទៅបែងចែកឱ្យសិស្សដែលម្នាក់ៗទទួលបានចំណែកដូចគ្នា ។ តើគេបែងចែកឱ្យសិស្សយ៉ាងច្រើនបានប៉ុន្មាននាក់ ?
7. ដានីរៀបផ្កាកុលាប 16 ទងនិងផ្កាសាគូរ៉ា 24 ទង ដាក់ក្នុងថូនីមួយៗមានចំនួនផ្កាស្មើគ្នា ។ តើដានីត្រូវការថូច្រើនបំផុតប៉ុន្មាន ដើម្បីរៀបផ្កានោះអស់ ?
8. ធារីរៀបស្វាយទុំ 24 ផ្លែនិងក្រូច ឃ្វិច 32 ផ្លែដាក់ក្នុងថាស ។ ថាសនីមួយៗមានផ្លែឈើពីរមុខដូចៗគ្នា ។ តើនាងត្រូវការថាសច្រើនបំផុតប៉ុន្មាន ដើម្បីរៀបផ្លែឈើនោះអស់ ?

www.elibraryofcambodia.org

9. បុប្ផាបោសផ្ទះរាល់ 4 ថ្ងៃម្តង ចិន្តាបោសផ្ទះរាល់ 6 ថ្ងៃម្តង ។ អ្នកទាំងពីរបោសរួមគ្នានៅថ្ងៃទី1 នៃខែមួយ ។ តើអ្នកទាំងពីរបោសរួមគ្នាទៀតលើកទី2 និងលើកទី3 នៅថ្ងៃទីប៉ុន្មាន ?

10. ចូរប្រៀបធៀប $12\times 18$ និង ត $(12;18)\times$ ព $(12;18)$ ។

11. សិស្ស A និងសិស្ស B រត់ចេញពីទី 0 ដំណាលគ្នា ។ ដោយដឹងថាសិស្ស A រត់បាន 6 ជុំក្នុង 1mn ហើយសិស្ស B រត់បាន 8 ជុំក្នុង 1mn ។ តើប៉ុន្មាននាទីក្រោយមក ទើបអ្នកទាំងពីរបានមកដល់ទី 0 ដំណាលគ្នាម្តងទៀត ?




12. ក្រុមអនាម័យទឹកស្អាត 3 ក្រុម បានចេញទៅជីកអណ្តូងជូនប្រជាជនតាមខេត្តនានា ។ ក្រុមទីមួយ 3 ខែចេញម្តង ក្រុមទីពីរ 4 ខែចេញម្តង ក្រុមទីបី 6 ខែចេញម្តង ។ លើកទីមួយ ក្រុមទាំងបីចេញព្រមគ្នានៅខែមករាឆ្នាំ ។ តើប៉ុន្មានខែទៅមុខទៀត ទើបក្រុមទាំងបីបានចេញព្រមគ្នាម្តងទៀត ? នៅខែណា ?

13. នាឡិកាបីរោទិ៍ក្នុងរយៈពេលផ្សេងៗគ្នា ។ នាឡិកាទីមួយរោទិ៍រាល់ 10 នាទី នាឡិកាទីពីររោទិ៍ រាល់ 15 នាទី និងនាឡិកាទីបីរោទិ៍រាល់ 20 នាទី ។ រករយៈពេលខ្លីបំផុតដែលនាឡិកាទាំងបីរោទិ៍ព្រមគ្នាទៀត បន្ទាប់ពីវាបានរោទិ៍ព្រមគ្នាម្តងរួចហើយ ។



www.elibraryofcambodia.org

# 10 វិធីបូកនិងវិធីដកប្រភាគ

## ភាគបែងរួមនៃប្រភាគ

ក. រកភាគបែងរួមនៃប្រភាគ $\frac{2}{3}$ និង $\frac{1}{5}$

$$\frac{2}{3} = \frac{2\times5}{3\times5} = \frac{10}{15}$$

$$\frac{1}{5} = \frac{1\times3}{5\times3} = \frac{3}{15}$$




ដូចនេះភាគបែងរួមនៃប្រភាគ $\frac{2}{3}$ និង $\frac{1}{5}$ គឺ 15 ។

ខ. រកភាគបែងរួមនៃប្រភាគ $\frac{1}{3}$ ; $\frac{2}{5}$ និង $\frac{4}{7}$

$$\frac{1}{3} = \frac{1\times5\times7}{3\times5\times7} = \frac{35}{105}$$

$$\frac{2}{5} = \frac{2\times3\times7}{5\times3\times7} = \frac{42}{105}$$

$$\frac{4}{7} = \frac{4\times3\times5}{7\times3\times5} = \frac{60}{105}$$




ដូចនេះភាគបែងរួមនៃប្រភាគ $\frac{1}{3}$ ; $\frac{2}{5}$ និង $\frac{4}{7}$ គឺ 105 ។

ភាគបែងរួមនៃប្រភាគពីរ ឬច្រើនគឺជាផលគុណភាគបែងនៃប្រភាគទាំងនោះ ។


www.elibraryofcambodia.org

## លំហាត់

1. រកភាគបែងរួមនៃប្រភាគខាងក្រោម

ក. $\frac{1}{2}$ និង $\frac{1}{3}$

ខ. $\frac{2}{3}$ និង $\frac{4}{5}$

គ. $\frac{3}{5}$ និង $\frac{6}{7}$

ឃ. $\frac{4}{8}$ និង $\frac{5}{9}$

ង. $\frac{5}{21}$ និង $\frac{15}{52}$

ច. $\frac{11}{31}$ និង $\frac{25}{100}$

ឆ. $\frac{3}{5}$ ; $\frac{1}{9}$ និង $\frac{1}{2}$

ជ. $\frac{3}{12}$ ; $\frac{6}{20}$ និង $\frac{15}{32}$

ឈ. $\frac{13}{32}$ ; $\frac{11}{25}$ និង $\frac{20}{110}$

ញ. $\frac{3}{5}$ ; $\frac{4}{7}$ និង $\frac{6}{17}$

ដ. $\frac{3}{5}$ ; $\frac{1}{9}$ និង $\frac{1}{2}$

ឋ. $\frac{13}{35}$ ; $\frac{20}{21}$ និង $\frac{35}{200}$ ។

2. ចូរសម្រួលប្រភាគរួចរកភាគបែងរួម

ក. $\frac{2}{4}$ និង $\frac{5}{10}$

ខ. $\frac{3}{12}$ និង $\frac{8}{20}$

គ. $\frac{15}{20}$ និង $\frac{3}{9}$

ឃ. $\frac{8}{14}$ និង $\frac{5}{15}$

ង. $\frac{24}{32}$ និង $\frac{25}{45}$

ច. $\frac{18}{42}$ និង $\frac{60}{108}$

ឆ. $\frac{6}{15}$ ; $\frac{4}{18}$ និង $\frac{3}{21}$

ជ. $\frac{32}{72}$ ; $\frac{15}{45}$ និង $\frac{7}{28}$

ឈ. $\frac{30}{35}$ ; $\frac{40}{20}$ និង $\frac{45}{72}$

ញ. $\frac{10}{20}$ ; $\frac{15}{35}$ និង $\frac{50}{100}$

ដ. $\frac{15}{25}$ ; $\frac{30}{20}$ និង $\frac{25}{200}$

ឋ. $\frac{12}{20}$ ; $\frac{2}{4}$ និង $\frac{13}{15}$

ឌ. $\frac{1}{35}$ ; $\frac{3}{70}$ និង $\frac{6}{61}$

ឍ. $\frac{4}{13}$ ; $\frac{1}{23}$ និង $\frac{12}{101}$ ។



www.elibraryofcambodia.org

## របៀបរកភាគបែងរួមតូចបំផុតតាមពហុគុណរួមតូចបំផុត

ក. រកភាគបែងរួមតូចបំផុតនៃប្រភាគ $\frac{2}{3}$ ; $\frac{3}{4}$

ពហុគុណនៃ 3 គឺ 3 ; 6 ; 9 ; [12] ; 18 ; ...

ពហុគុណនៃ 4 គឺ 4 ; 8 ; [12] ; 16

ដូចនេះ ភាគបែងរួមតូចបំផុតនៃប្រភាគ $\frac{2}{3}$ ; $\frac{3}{4}$ គឺ 12 ។

ខ. រកភាគបែងរួមតូចបំផុតនៃប្រភាគ $\frac{2}{3}$ ; $\frac{3}{4}$ និង $\frac{5}{8}$

ពហុគុណនៃ 3 គឺ 3 ; 6 ; 9 ; 12 ; 18 ; 21 ; [24] ; 27 ; ...

ពហុគុណនៃ 4 គឺ 4 ; 8 ; 12 ; 16 ; 20 ; [24] ; 28 ; ...

ពហុគុណនៃ 8 គឺ 8 ; 16 ; [24] ; 32

ដូចនេះ ភាគបែងរួមតូចបំផុតនៃប្រភាគ $\frac{2}{3}$ ; $\frac{3}{4}$ និង $\frac{5}{8}$ គឺ 24 ។

> ភាគបែងរួមតូចបំផុតនៃប្រភាគពីរ ឬច្រើនជាពហុគុណរួមតូចបំផុតនៃភាគបែងទាំងនោះ ។

## លំហាត់

រកភាគបែងរួមតូចបំផុតនៃប្រភាគខាងក្រោម

ក. $\frac{1}{4}$; $\frac{2}{5}$ និង $\frac{3}{6}$

ខ. $\frac{5}{7}$; $\frac{3}{10}$ និង $\frac{4}{5}$

គ. $\frac{1}{5}$; $\frac{3}{7}$ និង $\frac{5}{14}$

ឃ. $\frac{1}{6}$; $\frac{3}{8}$ និង $\frac{7}{12}$

ង. $\frac{1}{2}$; $\frac{3}{9}$ និង $\frac{2}{3}$

ច. $\frac{7}{25}$ និង $\frac{6}{5}$

ឆ. $\frac{1}{2}$; $\frac{3}{4}$; $\frac{1}{12}$ និង $\frac{7}{27}$

ជ. $\frac{3}{8}$; $\frac{4}{6}$; $\frac{1}{16}$ និង $\frac{3}{36}$ ។



www.elibraryofcambodia.org

## របៀបរកភាគបែងរួមតូចបំផុតតាមផលគុណកត្តាបឋម

ក. រកភាគបែងរួមតូចបំផុតនៃ $\frac{1}{6}$ និង $\frac{3}{8}$

ពហុគុណរួមតូចបំផុតនៃ (6 ; 8)

$$6 = 2 \times 3$$
$$8 = 2 \times 2 \times 2$$
$$ព\ (6 ; 8) = 2 \times 2 \times 2 \times 3 = 24$$



ដូចនេះ ភាគបែងរួមតូចបំផុតនៃ $\frac{1}{6}$ និង $\frac{3}{8}$ គឺ 24 ។

ខ. រកភាគបែងរួមតូចបំផុតនៃ $\frac{1}{8}$; $\frac{1}{12}$ និង $\frac{1}{10}$

ពហុគុណរួមតូចបំផុតនៃ (8; 12; 10)



$$8 = 2 \times 2 \times 2$$
$$12 = 2 \times 2 \times 3$$
$$10 = 2 \times 5$$
$$ព\ (8, 12, 10) = 2 \times 2 \times 5 \times 3 \times 2 = 120$$

ដូចនេះ ភាគបែងរួមតូចបំផុតនៃ $\frac{1}{8}$; $\frac{1}{12}$ និង $\frac{1}{10}$ គឺ 120 ។

ដើម្បីរកភាគបែងរួមតូចបំផុតតាមផលគុណកត្តាបឋម យើងត្រូវ :

1. បំបែកភាគបែងទាំងនោះជាផលគុណកត្តាបឋម
2. គុណកត្តាបឋមរួមនិងកត្តាបឋមមិនរួម ។

## លំហាត់

រកភាគបែងរួមតូចបំផុតនៃប្រភាគខាងក្រោម

ក. $\frac{3}{7}$ និង $\frac{4}{21}$ ខ. $\frac{7}{15}$ និង $\frac{6}{35}$ គ. $\frac{3}{31}$; $\frac{4}{62}$ និង $\frac{7}{32}$ ឃ. $\frac{1}{20}$; $\frac{3}{100}$ និង $\frac{14}{200}$ ។



www.elibraryofcambodia.org

# វិធីបូកប្រភាគមានភាគបែងខុសគ្នា

ក. គណនា $\frac{2}{5}+\frac{3}{4}=\square$




តម្រូវភាគបែងរួមនៃប្រភាគ $\frac{2}{5}$ ; $\frac{3}{4}$

ភាគបែងរួមតូចបំផុតនៃ $\frac{2}{5}$ និង $\frac{3}{4}$ គឺ 20

$\frac{2}{5}=\frac{2\times 4}{5\times 4}=\frac{8}{20}=\square$

$\frac{3}{4}=\frac{3\times 5}{4\times 5}=\frac{15}{20}$

ដូចនេះ $\frac{2}{5}+\frac{3}{4}=\frac{8}{20}+\frac{15}{20}=\frac{8+15}{20}=\frac{23}{20}$ ។

ខ. គណនា $\frac{1}{5}+\frac{3}{10}+\frac{6}{20}$

តម្រូវភាគបែងរួមនៃប្រភាគ $\frac{1}{5}$ ; $\frac{3}{10}$ និង $\frac{6}{20}$

ភាគបែងរួមតូចបំផុតនៃ $\frac{1}{5}$ ; $\frac{3}{10}$ និង $\frac{6}{20}$ គឺ 20

$\frac{1}{5}=\frac{1\times 4}{5\times 4}=\frac{4}{20}$




$\frac{3}{10}=\frac{3\times 2}{10\times 2}=\frac{6}{20}$

$\frac{1}{5}+\frac{3}{10}+\frac{6}{20}=\frac{4}{20}+\frac{6}{20}+\frac{6}{20}=\frac{4+6+6}{20}=\frac{16}{20}=\frac{4}{5}$

ដូចនេះ $\frac{1}{5}+\frac{3}{10}+\frac{6}{20}=\frac{4}{5}$ ។

ដើម្បីបូកប្រភាគមានភាគបែងខុសគ្នា យើងត្រូវតម្រូវភាគបែងឱ្យដូចគ្នា រួចបូកភាគយកនិងភាគយក រីឯភាគបែងរក្សាទុកនៅដដែល ។

www.elibraryofcambodia.org

## លំហាត់

1. ចូរបូកប្រភាគខាងក្រោម

ក. $\frac{1}{6}+\frac{1}{3}$ ខ. $\frac{1}{4}+\frac{1}{8}$ គ. $\frac{3}{8}+\frac{1}{2}$

ឃ. $\frac{7}{16}+\frac{1}{2}$ ង. $\frac{3}{8}+\frac{1}{4}$ ច. $\frac{5}{12}+\frac{1}{3}$

ឆ. $\frac{7}{8}+\frac{4}{5}+\frac{5}{6}$ ជ. $\frac{4}{15}+\frac{7}{30}+\frac{20}{45}$ ឈ. $\frac{6}{25}+\frac{1}{8}+\frac{4}{35}$ ។

2. ចូរបំពេញតារាងខាងក្រោម

(+ →, + ↓)

| | | |
|---|---|---|
| $\frac{2}{21}$ | $\frac{2}{7}$ | ? |
| $\frac{2}{3}$ | $\frac{5}{6}$ | ? |
| ? | ? | |

(+ →, + ↓)

| | | | |
|---|---|---|---|
| $\frac{2}{3}$ | $\frac{1}{6}$ | $\frac{4}{12}$ | ? |
| $\frac{3}{5}$ | $\frac{1}{25}$ | $\frac{14}{50}$ | ? |
| $\frac{7}{9}$ | $\frac{4}{18}$ | $\frac{5}{9}$ | ? |
| ? | ? | ? | ? |

3. ចូរបំពេញតារាងតាមលំនាំគំរូខាងក្រោម

| A | B | C | B + C |
|---|---|---|---|
| $\frac{1}{2}$ | $\frac{1}{2}$ | $\frac{1}{2}$ | 1 |
| $\frac{1}{2}+\frac{1}{4}$ | $\frac{3}{4}$ | $\frac{1}{4}$ | 1 |
| $\frac{1}{2}+\frac{1}{4}+\frac{1}{8}$ | $\frac{7}{8}$ | $\frac{1}{8}$ | 1 |
| $\frac{1}{2}+\ldots+\ldots+\frac{1}{16}$ | $\frac{15}{16}$ | $\frac{1}{16}$ | 1 |
| $\ldots+\ldots+\ldots+\ldots+\frac{1}{32}$ | ... | ... | ... |



www.elibraryofcambodia.org

## ចំណោទ

1. ក្នុងមួយថ្ងៃ ពូសំលើកទំនប់បាន $\frac{7}{8}$m រីឯមីងសានលើកទំនប់បាន $\frac{8}{16}$m ។ តើទាំងពីរនាក់លើកទំនប់ក្នុងមួយថ្ងៃបានប៉ុន្មានម៉ែត្រ ?
2. បូណាប្រើសាប៊ូបោកខោអាវអស់ $\frac{1}{2}$kg ឯតារីប្រើសាប៊ូអស់ $\frac{4}{8}$kg ។ តើអ្នកទាំងពីរប្រើសាប៊ូអស់ប៉ុន្មានគីឡូក្រាម ?
3. មីងចាន់ទិញសាច់ជ្រូកទម្ងន់ $\frac{5}{6}$kg និងសាច់គោទម្ងន់ $\frac{1}{2}$kg ។ តើសាច់ទាំងពីរមុខមានទម្ងន់ប៉ុន្មានគីឡូក្រាម ?
4. តានីញ៉ាំនំខ្ទឹកលើកទីមួយអស់ $\frac{2}{7}$ និងលើកទីពីរអស់ $\frac{1}{3}$ ។ តើនំខ្ទឹកដែលតានីញ៉ាំទាំងពីរលើកអស់ប៉ុន្មាន ?
5. ពូសំប្រមូលផលស្រូវវស្សាបាន $\frac{7}{8}$ តោន ស្រូវប្រាំងបាន $\frac{13}{25}$ តោន និងស្រូវប្រដេញទឹកបាន 900kg ។

   ក. តើពូសំប្រមូលផលស្រូវវស្សា និងស្រូវប្រាំងបានប៉ុន្មានតោន ?

   ខ. តើពូសំប្រមូលផលស្រូវទាំងអស់បានប៉ុន្មានតោន ? (1 តោន = 1000kg )
6. ចម្ងាយផ្លូវពីផ្ទះសុខាទៅសាលារៀនមានប្រវែង $\frac{1}{2}$km ពីសាលារៀនទៅសាលាឃុំមានប្រវែង $\frac{8}{10}$km និងពីសាលាឃុំទៅមណ្ឌលសុខភាពមានប្រវែង 1500m ។

   ក. តើចម្ងាយផ្លូវពីសាលារៀនទៅមណ្ឌលសុខភាពមានប្រវែងប៉ុន្មានគីឡូម៉ែត្រ ?

   ខ. តើចម្ងាយផ្លូវពីផ្ទះសុខាទៅមណ្ឌលសុខភាពមានចម្ងាយប៉ុន្មានគីឡូម៉ែត្រ ?

   $(1\text{km} = 1000\text{m} \;;\; 1\text{m} = \frac{1}{1000}\text{km})$



www.elibraryofcambodia.org

## វិធីដកប្រភាគមានភាគបែងខុសគ្នា

ក. គណនា $\frac{5}{6}-\frac{1}{4}=\square$

ព $(6\ ;\ 4)$

$6 = 2\times 3\ ;\ 4 = 2\times 2$

ព $(6;4) = 2\times 2\times 3 = 12$

ភាគបែងរួមស្មើ 12

$$\frac{5}{6}=\frac{5\times 2}{6\times 2}=\frac{10}{12}$$

$$\frac{1}{4}=\frac{1\times 3}{4\times 3}=\frac{3}{12}$$

$$\frac{5}{6}-\frac{1}{4}=\frac{10}{12}-\frac{3}{12}=\frac{10-3}{12}=\frac{7}{12}$$

ដូចនេះ $\frac{5}{6}-\frac{1}{4}=\frac{7}{12}$ ។

ខ. គណនា $\frac{1}{2}-\frac{1}{3}=\square$

ព $(2;3) = 2\times 3 = 6$

ភាគបែងរួមស្មើ 6

$$\frac{1}{2}=\frac{1\times 3}{2\times 3}=\frac{3}{6}\ ;\ \frac{1}{3}=\frac{1\times 2}{3\times 2}=\frac{2}{6}\ ;\ \frac{1}{2}-\frac{1}{3}=\frac{3}{6}-\frac{2}{6}=\frac{3-2}{6}=\frac{1}{6}$$

ដូចនេះ $\frac{1}{2}-\frac{1}{3}=\frac{1}{6}$ ។

ដើម្បីដកប្រភាគដែលមានភាគបែងខុសគ្នា គេត្រូវតម្រូវភាគបែងឱ្យដូចគ្នា រួចដកភាគយកនឹងភាគយក រីឯភាគបែងរក្សាទុកនៅដដែល ។



www.elibraryofcambodia.org

## លំហាត់

1. ចូរបំពេញ $\square$ ខាងក្រោម

ក. $\frac{2}{3}-\frac{1}{4}=\frac{\square}{\square}-\frac{\square}{\square}=\frac{\square}{\square}$ ខ. $\frac{7}{10}-\frac{4}{9}=\frac{\square}{\square}-\frac{\square}{\square}=\frac{\square}{\square}$

គ. $\frac{5}{6}-\frac{3}{4}=\frac{\square}{\square}-\frac{\square}{\square}=\frac{\square}{\square}$ ឃ. $\frac{13}{24}-\frac{3}{8}=\frac{\square}{\square}-\frac{\square}{\square}=\frac{\square}{\square}$

2. ចូរគណនាផលដកប្រភាគខាងក្រោម

ក. $\frac{1}{2}-\frac{1}{4}$ ខ. $\frac{3}{4}-\frac{1}{2}$ គ. $\frac{3}{4}-\frac{3}{8}$

ឃ. $\frac{1}{2}-\frac{1}{8}$ ង. $\frac{7}{10}-\frac{1}{4}$ ច. $\frac{5}{6}-\frac{2}{3}$

ឆ. $\frac{7}{3}-\frac{4}{9}$ ជ. $\frac{5}{8}-\frac{1}{4}$ ឈ. $\frac{7}{8}-\frac{3}{4}$

ញ. $\frac{9}{4}-\frac{7}{6}$ ដ. $\frac{9}{10}-\frac{3}{5}$ ឋ. $\frac{7}{8}-\frac{3}{4}$

ឌ. $\frac{1}{2}-\frac{1}{6}$ ឍ. $\frac{3}{4}-\frac{1}{8}$ ណ. $\frac{1}{2}-\frac{3}{8}$ ។

3. ចូរបំពេញចន្លោះតាមលំនាំគំរូខាងក្រោម

| | | |
|---|---|---|
| $\frac{2}{2}-\frac{1}{2}$ | $\frac{1}{2}$ | $=\frac{1}{2}$ |
| $\frac{4}{4}-\frac{1}{4}$ | $\frac{1}{2}+\frac{1}{4}$ | $=\frac{3}{4}$ |
| $\frac{8}{8}-\frac{1}{8}$ | $\frac{1}{2}+\frac{1}{4}+\frac{1}{8}$ | $=\frac{7}{8}$ |
| …… | $\frac{1}{2}+$ …… $+$ …… $+\frac{1}{16}$ | $=$ …… |
| $\frac{32}{32}-\frac{1}{32}$ | $\frac{1}{2}+\frac{1}{4}+\frac{1}{8}+\frac{1}{16}+\frac{1}{32}$ | $=\frac{31}{32}$ |
| …… | …… + …… + …… + …… + …… + …… | = …… ។ |

www.elibraryofcambodia.org

## ចំណោទ

ឧទាហរណ៍ 1៖ សុខធ្វើដំណើរពីក្រុង A ទៅក្រុង B ដែលមានចម្ងាយ 150km ។ ដំបូងសុខជិះម៉ូតូបាន $\frac{1}{3}$ នៃចម្ងាយផ្លូវ បន្ទាប់មកគាត់បន្តដំណើរដោយរថយន្ត ។ រកចម្ងាយផ្លូវដែលសុខជិះរថយន្ត ។






**ចម្លើយ**

**របៀបទី 1**

ចម្ងាយផ្លូវដោយម៉ូតូតាងដោយប្រភាគ $\frac{1}{3}$

រកចម្ងាយផ្លូវដោយរថយន្តតាងដោយ $1-\frac{1}{3}=\frac{2}{3}$

ចម្ងាយផ្លូវដែលសុខធ្វើដំណើរតាមរថយន្ត

$150km \times \frac{2}{3} = 100km$

ឆ្លើយថា ៖ ចម្ងាយផ្លូវសុខជិះរថយន្ត គឺ 100km

**របៀបទី 2**

រកចម្ងាយផ្លូវដោយម៉ូតូ

$150km \times \frac{1}{3} = 50km$

រកចម្ងាយផ្លូវដោយរថយន្ត

$150km - 50km = 100km$

ឆ្លើយថា ៖ ចម្ងាយផ្លូវសុខជិះរថយន្ត គឺ 100km

ផ្ទៀងផ្ទាត់ ៖ ចម្ងាយសរុប $50km + 100km = 150km$ ។



www.elibraryofcambodia.org

ឧទាហរណ៍ 2: ក្រុមហ៊ុនមួយនាំម៉ូតូចូល 75 គ្រឿង លើកទី 1 លក់បាន $\frac{2}{5}$ និងលើកទី 2 លក់បាន $\frac{1}{3}$ ។ រកចំនួនម៉ូតូដែលនៅសល់ ។



**ចម្លើយ**



របៀបទី 1

ម៉ូតូដែលបានលក់ទាំងពីរលើក $\frac{2}{5}+\frac{1}{3} = \frac{6+5}{15} = \frac{11}{15}$

ម៉ូតូដែលនៅសល់ $1-\frac{11}{15} = \frac{4}{15}$

ចំនួនម៉ូតូដែលនៅសល់ $75\times\frac{4}{15} = 5\times 4 = 20$ គ្រឿង

ឆ្លើយថា : ចំនួនម៉ូតូនៅសល់ 20 គ្រឿង ។



របៀបទី 2

រកចំនួនម៉ូតូដែលបានលក់នៅលើកទី 1

$\frac{2}{5}\times 75 = 2\times 15 = 30$ គ្រឿង

រកចំនួនម៉ូតូដែលបានលក់នៅលើកទី 2

$\frac{1}{3}\times 75 = 25$ គ្រឿង

រកចំនួនម៉ូតូដែលនៅសល់

$75-(30+25) = 75-55 = 20$ គ្រឿង ។

ឆ្លើយថា : ម៉ូតូដែលនៅសល់គឺ 20 គ្រឿង ។

**ផ្ទៀងផ្ទាត់** : ចំនួនម៉ូតូសរុប $30+25+20 = 75$ ។

www.elibraryofcambodia.org

ឧទាហរណ៍ 3៖ ក្នុងថ្នាក់រៀនមួយសិស្សដែលប្រឡងបានពិន្ទុមធ្យមមានចំនួន $\frac{1}{2}$ ហើយសិស្សដែលទទួលបានពិន្ទុល្អមាន $\frac{1}{3}$ និងសិស្សទទួលបានពិន្ទុក្រោមមធ្យមមានចំនួន 7 នាក់ ។ តើថ្នាក់រៀននោះមានចំនួនសិស្សប៉ុន្មាននាក់ ?



**ចម្លើយ**

សិស្សបានពិន្ទុមធ្យម $\frac{1}{2} = \frac{3}{6}$

សិស្សបានពិន្ទុល្អ $\frac{1}{3} = \frac{2}{6}$

ដូចនេះ សិស្សក្រោមមធ្យមតាងដោយប្រភាគ

$1 - \left(\frac{3}{6} + \frac{2}{6}\right) = 1 - \frac{5}{6} = \frac{1}{6}$




ក្នុងករណីនេះ គេតាងសិស្សសរុបដោយអង្កត់មួយ រួចចែកអង្កត់នោះជា 6 ចំណែកស្មើគ្នា

3 ចំណែកតាងឱ្យសិស្សបានពិន្ទុមធ្យម

2 ចំណែកតាងឱ្យសិស្សបានពិន្ទុល្អ

1 ចំណែកតាងឱ្យសិស្សបានពិន្ទុក្រោមមធ្យម

1 ចំណែកស្មើនឹង 7 នាក់

ដូចនេះ សិស្សបានពិន្ទុមធ្យមមានចំនួន

$3 \times 7 = 21$ នាក់

សិស្សបានពិន្ទុល្អមានចំនួន $2 \times 7 = 14$ នាក់

សិស្សបានពិន្ទុក្រោមមធ្យមមានចំនួន

$1 \times 7 = 7$ នាក់

ឆ្លើយថា ៖ សិស្សសរុបចំនួន $21 + 14 + 7 = 42$ នាក់

ផ្ទៀងផ្ទាត់៖ សិស្សបានពិន្ទុមធ្យម $\frac{21}{42} = \frac{1}{2}$ និងសិស្សបានពិន្ទុល្អ $\frac{14}{42} = \frac{1}{3}$ ។



www.elibraryofcambodia.org

## ចំណោទ

1. ក្នុងមួយថ្ងៃ ពូសំលើកទំនប់បាន $\frac{7}{8}$m រីឯមីងសានលើកទំនប់បាន $\frac{8}{16}$m ។ តើនរណាលើកទំនប់បានវែងជាង ? វែងជាងប៉ុន្មានម៉ែត្រ ?
2. ម្ដាយសុខាលក់សំពត់ហូលលើកទី1អស់ $\frac{4}{5}$m លើកទី 2អស់ $\frac{6}{8}$m និងលើកទី3 អស់ $\frac{4}{6}$m ។ តើម្ដាយសុខាលក់សំពត់ហូលទាំង3លើកអស់ប៉ុន្មានម៉ែត្រ ?
3. ម្ដាយសំប្រើស្ករត្នោតធ្វើនំអស់ $\frac{1}{2}$kg និងប្រើម្សៅអង្ករច្រើនជាងស្ករ $\frac{5}{3}$kg ។ តើម្ដាយ សំ ប្រើម្សៅអង្ករប៉ុន្មានគីឡូក្រាមដើម្បីធ្វើនំ ?
4. ដបមួយមានទឹក $\frac{8}{25}\ell$ ។ តើត្រូវថែមទឹកប៉ុន្មានទៀតដើម្បីឱ្យបានទឹក $1\ell$ ?
5. សុភាពទិញសាច់ជ្រូក $\frac{5}{6}$kg និងទិញសាច់គោ $\frac{4}{3}$kg ។ សាច់ជ្រូក និងសាច់គោមានតម្លៃស្មើគ្នាគឺ 1kg ថ្លៃ 24 000 ៛ ។ តើសុភាពចំណាយអស់ប្រាក់ប៉ុន្មានរៀលក្នុងការទិញសាច់គោនិងសាច់ជ្រូក ?
6. កង់រទេះទី1មានកាំប្រវែង $\frac{7}{9}$m ហើយកង់រទេះទី2 មានកាំប្រវែង $\frac{17}{20}$m ។ តើកាំរទេះទាំងពីរខុសគ្នាប៉ុន្មានម៉ែត្រ ?
7. ប្រេងក្នុងធុងទី1មានទម្ងន់ $\frac{1}{2}$ តោន និងប្រេងក្នុងធុងទី2មានទម្ងន់ $\frac{3}{8}$ តោន ។
   ក. តើប្រេងទាំងពីរធុងមានទម្ងន់ប៉ុន្មានគីឡូក្រាម ?
   ខ. តើប្រេងក្នុងធុងទាំងពីរមានទម្ងន់ខុសគ្នាប៉ុន្មាន ?
8. ពលករមួយក្រុមជីកប្រឡាយថ្ងៃទី1បានប្រវែង $\frac{4}{5}$km ថ្ងៃទី 2ជីកបានខ្លីជាងថ្ងៃទី1 ប្រវែង $\frac{1}{10}$km ។ គេដឹងថាក្នុងការជីកប្រឡាយ 1m ត្រូវចំណាយប្រាក់ 35 000 ៛ ។ តើទាំងពីរថ្ងៃត្រូវការចំណាយប្រាក់អស់ប៉ុន្មាន ?

www.elibraryofcambodia.org

9. យាយម៉ៅមានសំពត់ផាមួងប្រវែង 15m ។ គាត់កាត់លក់លើកទី1 អស់ $\frac{8}{5}$m លើកទី2 អស់ $\frac{7}{4}$m និងលើកទី3 អស់ $\frac{1}{2}$m ។ តើយាយម៉ៅសល់សំពត់ផាមួងប្រវែងប៉ុន្មានម៉ែត្រ ?

10. បូណាធ្វើដំណើរទៅលេងកំពតតាមរថភ្លើងហើយត្រឡប់មកវិញតាមរថយន្ត ។ គាត់ចំណាយប្រាក់ $\frac{1}{4}$ សម្រាប់ថ្លៃសំបុត្ររថភ្លើង និង $\frac{1}{3}$ សម្រាប់សំបុត្ររថយន្ត ។ មកដល់ផ្ទះវិញនៅសល់ប្រាក់ 20 000 ៛ ។

ក. តើមុនពេលទៅកំពតបូណាមានប្រាក់ប៉ុន្មាន ?

ខ. តើសំបុត្ររថភ្លើងថ្លៃប៉ុន្មានរៀល និងសំបុត្ររថយន្តថ្លៃប៉ុន្មានរៀល ?

11. បុគ្គលិកក្រុមហ៊ុនម្នាក់ទទួលប្រាក់បៀវត្ស 518 000 ៛ ក្នុងមួយខែ ។ គាត់ចំណាយ $\frac{4}{7}$ សម្រាប់ការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និង $\frac{1}{4}$ សម្រាប់ជូនឪពុកម្ដាយ ។ តើក្នុងមួយខែបុគ្គលិកក្រុមហ៊ុននោះនៅសល់ប្រាក់ប៉ុន្មាន ?

12. ក្រុមហ៊ុនមួយម៉ៅការជួសជុលផ្លូវថ្នល់ប្រវែង 60km ។ ដំណាក់ទី1 ជួសជុលបានប្រវែង $\frac{2}{5}$ នៃប្រវែងផ្លូវដែលត្រូវជួសជុលនិងដំណាក់ទី2 ជួសជុលបានប្រវែង $\frac{7}{10}$ នៃប្រវែងផ្លូវដែលនៅសល់ ។

ក. តើទាំងពីរដំណាក់ក្រុមហ៊ុននោះជួសជុលផ្លូវបានប្រវែងប៉ុន្មាន ?

ខ. តើប្រវែងផ្លូវដែលមិនទាន់បានជួសជុលនៅសល់ប៉ុន្មានគីឡូម៉ែត្រទៀត ?

13. ចាន់ណាមានសំពត់ប្រវែង $\frac{10}{3}$m ។ គាត់យកសំពត់នោះទៅកាត់អាវឱ្យបងអស់ $\frac{7}{8}$m និងកាត់សម្លៀកបំពាក់ឱ្យប្អូនអស់ $\frac{5}{3}$m ។ តើចាន់ណានៅសល់សំពត់ប៉ុន្មានម៉ែត្រ ?

14. ធុងមួយមានប្រេងសាំង 8 តោន ។ គេលក់លើកទី1 អស់ $\frac{12}{8}$ តោន និងលក់លើកទី2 អស់ $\frac{10}{16}$ តោន ។ តើប្រេងសាំងនៅសល់ក្នុងធុងមានទម្ងន់ប៉ុន្មានគីឡូក្រាម ?



www.elibraryofcambodia.org

15. ចម្ការចតុកោណកែងមួយមានបណ្តោយប្រវែង $\frac{1}{2}$km និងទទឹងខ្លីជាងបណ្តោយ $\frac{1}{4}$km ។

ក. តើចម្ការនោះមានបរិមាត្រប៉ុន្មានម៉ែត្រ ?

ខ. តើផ្ទៃក្រឡាចម្ការនោះមានទំហំប៉ុន្មានម៉ែត្រការេ ?

16. ចម្ការចតុកោណកែងមួយមានបណ្តោយប្រវែង $\frac{4}{5}$km និងទទឹងខ្លីជាងបណ្តោយ $\frac{1}{10}$km ។ កសិករលើកផ្លូវព័ទ្ធជុំវិញចម្ការនោះលើកទី1 បាន $\frac{1}{5}$km លើកទី2បាន $\frac{2}{10}$km និងលើកទី3បាន $\frac{1}{20}$km ។

ក. រកប្រវែងផ្លូវដែលត្រូវលើក ។

ខ. រកប្រវែងផ្លូវដែលកសិករលើកបាន ។

គ. រកប្រវែងផ្លូវដែលត្រូវលើកបន្ថែម ។

17. ចម្ងាយផ្លូវពីភ្នំពេញទៅក្រុងក្រចេះមានប្រវែង 315km ។ មករាធ្វើដំណើរពីភ្នំពេញទៅក្រុងក្រចេះ ជាដំបូងធ្វើដំណើរដោយជិះម៉ូតូបានប្រវែង $\frac{1}{5}$ នៃចម្ងាយផ្លូវ ។ បន្ទាប់មកធ្វើដំណើរដោយរថយន្តឈ្នួលបានប្រវែង $\frac{3}{10}$ នៃចម្ងាយផ្លូវ បន្តទៅទៀតធ្វើដំណើរដោយរថយន្តមិត្តភក្តិទើបដល់ក្រុងក្រចេះ ។
រកចម្ងាយផ្លូវដែលមករាធ្វើដំណើរដោយរថយន្តមិត្តភក្តិ ។

18. កសិករម្នាក់ប្រមូលផលពោតបាន $\frac{3}{2}$ តោន សណ្តែកសៀងបាន $\frac{7}{8}$ តោន និងល្ងបានផលតិចជាងពោត $\frac{1}{2}$ តោន ។

ក. តើកសិករនោះប្រមូលផលល្ងបានប៉ុន្មានគីឡូក្រាម ?

ខ. តើផលដំណាំទាំងបីមុខសរុបទាំងអស់ប៉ុន្មានគីឡូក្រាម ?

19. សៅនិងម៉ារីរួមគ្នាទិញរបស់មួយថ្លៃ 4800 ៛ សៅចេញប្រាក់ $\frac{2}{3}$ ហើយម៉ារីចេញប្រាក់ដែលនៅសល់ ។ តើម្នាក់ៗចេញប្រាក់ប៉ុន្មាន ?

www.elibraryofcambodia.org

20. សៀវភៅមួយប្រអប់មានទម្ងន់ 52kg ។ គេដឹងថាសៀវភៅនីមួយៗមានទម្ងន់ $\frac{3}{4}$kg ហើយប្រអប់មានទម្ងន់ 8kg ។ រកចំនួនសៀវភៅ ។

21. សុខធ្វើលំហាត់ត្រូវបាន 12 សំណួរត្រូវជា $\frac{3}{4}$ នៃសំណួរទាំងអស់ ។ តើសុខធ្វើខុសប៉ុន្មានសំណួរ ?

22. ក្នុងពិធីបុណ្យបីថ្ងៃ បូណាបានលក់អាវយឺតអស់ពាក់កណ្តាលនៅថ្ងៃទី 1 នៅថ្ងៃទី 2 លក់អស់ពាក់កណ្តាលនៃអាវដែលសល់ និងនៅថ្ងៃទី 3 លក់អស់ពាក់កណ្តាលនៃអាវដែលសល់ពីថ្ងៃទី 2 ហើយនៅសល់អាវ 4 ។ តើបូណាមានអាវសរុបប៉ុន្មានសម្រាប់លក់ ?

23. សុកមានកម្ពស់ $\frac{5}{4}$m ។ ស្រមោលរបស់វាមានប្រវែង $\frac{5}{2}$m នៃប្រវែងកម្ពស់ ។ រកប្រវែងស្រមោលរបស់សុក ។

24. ចម្ការមួយរាងចតុកោណកែង បណ្តោយមានប្រវែង $\frac{3}{4}$km ។ ទទឹងខ្លីជាងបណ្តោយ $\frac{1}{8}$km ។ គណនាបរិមាត្រចម្ការនោះ ។

25. ក្នុងភូមិមួយមានមនុស្សទៅបោះឆ្នោតជាបុរសចំនួន $\frac{1}{2}$ ហើយជាស្ត្រីចំនួន $\frac{1}{3}$ ហើយអ្នកដែលមិនបានទៅបោះឆ្នោតមានចំនួន 70 នាក់ ។ តើក្នុងភូមិនោះមានមនុស្សចុះឈ្មោះបោះឆ្នោតប៉ុន្មាននាក់ ?

26. ពីភ្នំពេញទៅអ្នកលឿងមានចម្ងាយផ្លូវ 60km ។ សុខាធ្វើដំណើរពីអ្នកលឿងទៅភ្នំពេញ ដំបូងជិះម៉ូតូបានចម្ងាយ $\frac{1}{6}$ នៃចម្ងាយផ្លូវ បន្ទាប់មកសុខាបន្តដំណើរដោយរថយន្ត ។ រកចម្ងាយផ្លូវដែលសុខាជិះរថយន្ត ។

27. កសិករម្នាក់មានស្រូវមួយជង្រុក គាត់លក់លើកទី 1 អស់ $\frac{1}{5}$ និងលើកទី 2 អស់ $\frac{3}{10}$ នៃស្រូវក្នុងជង្រុកហើយនៅសល់ស្រូវ 700kg ។

ក. តើកសិករនោះមានស្រូវទាំងអស់ប៉ុន្មានគីឡូក្រាម ?

ខ. តើកសិករនោះលក់ស្រូវទាំងពីរលើកអស់ប៉ុន្មានគីឡូក្រាម ?



www.elibraryofcambodia.org

# 11 វិធីគុណនិងវិធីចែកប្រភាគ

## វិធីគុណប្រភាគនឹងប្រភាគ

ក. គណនា $\frac{1}{2} \times \frac{1}{3} = \square$



$\frac{1}{3}$  $\frac{1}{2}$ នៃ $\frac{1}{3}$  $\frac{1}{2} \times \frac{1}{3} = \frac{1}{6}$

ដូចនេះ $\frac{1}{2} \times \frac{1}{3} = \frac{1 \times 1}{2 \times 3} = \frac{1}{6}$ ។

ខ. គណនា $\frac{2}{3} \times \frac{2}{5} = \square$



$\frac{2}{5}$  $\frac{2}{3}$ នៃ $\frac{2}{5}$  $\frac{2}{3} \times \frac{2}{5} = \frac{4}{15}$

ដូចនេះ $\frac{2}{3} \times \frac{2}{5} = \frac{2 \times 2}{3 \times 5} = \frac{4}{15}$ ។

ដើម្បីគុណប្រភាគនឹងប្រភាគគេគុណ ភាគយកនឹងភាគយក ហើយភាគបែងគុណនឹងភាគបែង ។



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្ទៅ យ៉ាតណៃ, ខ្ទៅ សុផល, ខ្ទៅ វិសាល, ខ្ទៅ វ៉ាមុន, ខ្ទៅ ភាពជា, ខ្ទៅ
ធំជើន និង ខ្ទៅ ភារី បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ទៅ ពាញ និង ឧបាសិកា ឈរ យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ ផួង កញ្ញា
ខែកុម្ភៈ ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "កម្មសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ទៅ ឃុនសរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org